NUM
2024

កត្តាកំណត់ចំនុកចិត្ត និងប្រសិទ្ធិភាពនៃការអនុវត្តលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ខេត្តប៉ៃលិន
អ៊ីវលី ច័ន្ទតាឫទ្ធិ

ក្រសួងអប់រំ យុវជន និងកីឡា
សាកលវិទ្យាល័យជាតិគ្រប់គ្រង
សាលាក្រោយបរិញ្ញាបត្រ

# កត្តាកំណត់ចំនុកចិត្ត និងប្រសិទ្ធិភាពនៃការអនុវត្ត លទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ខេត្តប៉ៃលិន

**អ៊ីវលី ច័ន្ទតាឫទ្ធិ**

និក្ខេបបទ ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់
ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

**ជំនាញ រដ្ឋបាលសាធារណៈ**

**ភ្នំពេញ**
ឆ្នាំ ២០២៤

ក្រសួងអប់រំ យុវជន និងកីឡា

សាកលវិទ្យាល័យជាតិគ្រប់គ្រង

សាលាក្រោយបរិញ្ញាបត្រ

**កត្តាកំណត់ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការ**
**អនុវត្តលទ្ធកម្មសាធារណៈនៅ**
**រដ្ឋបាលថ្នាក់ក្រោមជាតិ ខេត្តប៉ៃលិន**

**អ៊ីវលី ច័ន្ទតាឫទ្ធិ**

និក្ខេបបទដើម្បីបំពេញលក្ខខណ្ឌប្រឡងបញ្ចប់
ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

**សាស្ត្រាចារ្យដឹកនាំ**

**បណ្ឌិត ហេង សុភាព**

ភ្នំពេញ

ឆ្នាំ២០២៤

# លិខិតធានាអះអាង

ខ្ញុំបាទ សូមធានាអះអាងថា រាល់ខ្លឹមសារ និងការលើកឡើងក្នុងកិច្ចការ ស្រាវជ្រាវមួយនេះ គឺមានការបង្ហាញពីប្រភពដើម និងឯកសារយោងច្បាស់លាស់ ដែលសុទ្ធសឹងជាស្នាដៃស្រាវជ្រាវរបស់ខ្ញុំបាទផ្ទាល់ ដោយឥតមានការចម្លងចេញពី កិច្ចការរបស់អ្នកដទៃឡើយ។ ទាំងអស់នេះគឺជាការចងក្រងស្នាដៃថ្មីមួយរបស់ខ្ញុំបានក្នុងការខិតខំ ចងក្រង ប្រមូលឯកសារ និងរាល់ទិន្នន័យដែលពាក់ព័ន្ធ ដើម្បីបំពេញ លក្ខខណ្ឌក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឱ្យបានជោគជ័យ។



**អ៊ីវលី ច័ន្ទតាឫទ្ធិ**

សាកលវិទ្យាល័យជាតិគ្រប់គ្រង

ភ្នំពេញ

២០២៤

# សេចក្ដីថ្លែងអំណរគុណ

**ខ្ញុំបាទឈ្មោះ អ៊ីវលី ច័ន្ទតាឬទ្ធិ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើជំនាញរដ្ឋបាលសាធារណៈនៃសាកលវិទ្យាល័យ ជាតិគ្រប់គ្រងឆ្នាំសិក្សា ២០២១-២០២៣។ អស់រយៈពេល២ឆ្នាំនៃការសិក្សានៅសាកលវិទ្យាល័យ ខ្ញុំបាទបានឆ្លងកាត់នូវការខិតខំប្រឹងប្រែងដ៏ស្វិតស្វាញបំផុត ដោយចំណាយទាំងពេលវេលា កម្លាំងកាយ ប្រាជ្ញា ស្មារតីគ្រប់បែបយ៉ាងដើម្បីទទួលបាននូវលទ្ធផលជោគជ័យ និងសម្រេចបាននូវការរៀបចំសារណាបញ្ចប់ការសិក្សាមួយ ដែលប្រកបដោយផ្លែផ្កា។ តាមរយៈលទ្ធផលវិជ្ជមាននោះ យើងខ្ញុំសូមថ្លែងអំណរគុណ និងសម្ដែងនូវកតញ្ញូតាធម៌ ការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

**លោកឪពុក និងអ្នកម្ដាយ** ជាទីគោរព និងជាអ្នកមានគុណដ៏ខ្ពង់ខ្ពស់មិនអាចកាត់ថ្លៃបាន។ លោកបានពុះពារគ្រប់ឧបសគ្គដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្គត់ផ្គង់ទំនុកបម្រុង ទាំងសម្ភារៈ ហិរញ្ញវត្ថុ និងស្មារតីក្នុងការសិក្សា ព្រមទាំងជាទីប្រឹក្សាផ្ដល់យោបល់ដ៏សំខាន់បំផុតតាំងពីកូនចូលសិក្សាថ្នាក់បឋម រហូតបញ្ចប់ថ្នាក់ឧត្ដមសិក្សាយ៉ាងជោគជ័យ។ គុណដ៏ធំធេងរបស់លោកអ្នកមានគុណ កូននឹងខិតខំតបស្នងឱ្យអស់ពីកម្លាំងកាយ កម្លាំងចិត្តនៅថ្ងៃខាងមុខ ជាងនេះទៅទៀតខ្ញុំបាទនឹងប្ដេជ្ញាចិត្តថានឹងធ្វើតែអំពើល្អ ជួយកិច្ចការសង្គមជាតិ ធ្វើខ្លួនជាប្រជាពលរដ្ឋល្អ និងក្លាយជាធនធានមនុស្សដែលសង្គមជាតិកំពុងត្រូវការមិន អាចខ្វះបាន។

ឯកឧត្ដម សាស្ត្រាចារ្យ បណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ដែលបានគ្រប់គ្រង ដឹកនាំ បង្ហាត់ បង្រៀនទាំងទ្រឹស្ដី និងការអនុវត្តផ្ទាល់ប្រកបដោយការយកចិត្តទុកដាក់ និងទំនួលខុសត្រូវខ្ពស់ចំពោះនិស្សិតគ្រប់រូប ដោយពុំគិតពីការលំបាកនឿយហត់អ្វីឡើយ ខិតខំណែនាំ អប់រំ ប្រៀនប្រដៅ និងផ្ដល់ដំបូន្មានល្អៗ ដល់និស្សិតគ្រប់រូបប្រកបដោយបទពិសោធន៍ និងទំនួលខុសត្រូវខ្ពស់ ក្នុងគោលដៅអភិវឌ្ឍ ធនធានមនុស្សប្រកបដោយថាមពល និងចំណេះដឹងពិតប្រាកដដែលសង្គមជាតិត្រូវការ។

ជាពិសេសយើងខ្ញុំសូមគោរពការដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សាស្ត្រាចារ្យបណ្ឌិត **ហេង សុភាព** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីផ្ដល់នូវការណែនាំ គន្លឹះសំខាន់ៗក្នុងការ ស្រាវជ្រាវ និងរៀបចំការសរសេរនិក្ខេបបទ មតិយោបល់ និងកែសម្រួលសារណារបស់ខ្ញុំបាទ ដោយពុំខ្លាចនឿយហត់ដោយគ្មានការលាក់លៀម ប្រកបដោយស្នាមញញឹម និងក្ដីស្រលាញ់ចំពោះនិស្សិត។

# សេចក្តីសង្ខេប

ក្រោយពីខ្ញុំបាទបានទទួលការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញរដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ខ្ញុំបាទបានទទួលនូវចំណេះដឹងជាច្រើន ដែលទាក់ទងទៅនឹងការគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា និងចំណេះដឹងផ្សេងៗទៀត។ ជាពិសេស គឺបានធ្វើឱ្យខ្ញុំបាទអាចបោះជំហានមកដល់ដំណាក់កាលបញ្ចប់ការសិក្សា ផ្នែករដ្ឋបាលសាធារណៈនេះ ដោយសារការយកចិត្តទុកដាក់ និងការខិតខំប្រឹងប្រែងរបស់ខ្ញុំបាទ បូករួមទាំងការបង្ហាត់បង្រៀន ការផ្តល់អនុសាសន៍ និងការកែលម្អពីសំណាក់សាស្ត្រាចារ្យផងនោះ ទើបធ្វើឱ្យខ្ញុំបាទទទួលបានលទ្ធផលល្អជាទីគាប់ចិត្ត និងទទួលបាននូវឱកាសដ៏វិសេសមួយគឺ ការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

ដោយមើលឃើញថាការអនុវត្តកិច្ចលទ្ធកម្មសាធារណៈជាកាតព្វកិច្ចដែលត្រូវតែបំពេញរបស់ក្រសួង-ស្ថាប័ន និងជាកត្តាមួយដែលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ និងជួយកាត់បន្ថយការចំណាយខ្ជះខ្ជាយ ជាពិសេសដើម្បីឆ្លើយតបទៅនឹងប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពសន្សំសំចៃនៃការអនុវត្តថវិការបស់រាជរដ្ឋាភិបាលនៅតាមបណ្តារដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ដូចនេះហើយដើម្បីលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពសន្សំសំចៃក្នុងការអនុវត្តថវិកានៅក្នុងក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើកំណែទម្រង់ស្ទើរគ្រប់វិស័យទាំងអស់ ជាពិសេសកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

អាស្រ័យហេតុនេះហើយ ទើបជំរុញឱ្យខ្ញុំបាទ ធ្វើការសម្រេចចិត្តជ្រើសរើសយកការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី "កត្តាកំណត់ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តលទ្ធកម្មសាធារណនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ខេត្តប៉ៃលិន" ដើម្បីសិក្សាស្វែងយល់លម្អិតបន្ថែម និងជាពិសេសរួមចំណែកក្នុងការពង្រីកបន្ថែមទាក់ទងនឹងប្រធានបទនេះ។ ទន្ទឹមនឹងនេះខ្ញុំបាទសង្ឃឹមថាកិច្ចការស្រាវជ្រាវមួយនោះ នឹងក្លាយជាប្រទីបដ៏សំខាន់មួយសម្រាប់បំភ្លឺនូវទស្សនៈក្នុងការស្វែងយល់ពីឫសគល់នៃបញ្ហាទាំងឡាយដែលកើតមាននៅក្នុងការអនុវត្តនីតិវិធីកិច្ចលទ្ធកម្មសាធារណៈ ក៏ដូចជាការចូលរួមចំណែកផ្តល់អនុសាសន៍ក្នុងន័យកែលម្អ និងធ្វើឱ្យប្រសើរឡើង។

នៅទីបញ្ចប់ ខ្ញុំបាទសូមអភ័យទោសរាល់កំហុសឆ្គងទាំងឡាយ ទាំងខាងអក្ខរាវិរុទ្ធ និងពាក្យពេចន៍មួយចំនួន ដែលនឹងអាចកើតមានឡើងដោយអចេតនា។ ខ្ញុំបាទរីករាយ និងស្វាគមន៍ដោយក្តីសោមនស្ស ទទួលយករាល់មតិទិតៀនរិះគន់ក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋាន ដើម្បីអភិវឌ្ឍស្នាដៃមួយនេះឱ្យកាន់តែមានគុណភាព និងសុក្រឹតភាពថែមទៀតដើម្បីជាប្រយោជន៍ដល់អ្នកសិក្សាជំនាន់ក្រោយៗទៀត។

# មាតិកា

ទំព័រ


ជំពូកទី១....................................................................................................................១

សេចក្តីផ្តើម ...................................................................................................................១

១.១ សាវតានៃការសិក្សា.......................................................................................................១

១.២ ការថ្លែងបញ្ហា.......................................................................................................... ៣

១.៣ សំណួរស្រាវជ្រាវ..........................................................................................................៥

១.៤ គោលបំណងនៃការសិក្សាស្រាវជ្រាវ .................................................................................៥

១.៥ ការតាងសម្មតិកម្ម ........................................................................................................៥

១.៦ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ...............................................................................៦

១.៧ សារៈសំខាន់នៃការស្រាវជ្រាវ .........................................................................................៦

១.៨ ប្លង់នៃការសិក្សា..........................................................................................................៨

ជំពូកទី២៖ ការរំលឹកទ្រឹស្តី.............................................................................................. ១០

២.១. សេចក្តីផ្តើម ............................................................................................................. ១០

២.២ ពាក្យគន្លឹះ................................................................................................................ ១០

២.៣.ក្របខណ្ឌទ្រឹស្តីនៃលទ្ធកម្មសាធារណៈ ............................................................................ ១៦

២.៤ ក្របខណ្ឌលទ្ធកម្មសាធារណៈនៅកម្ពុជា ......................................................................... ១៦

២.៥.ឧត្តមានុវត្តន៍អន្តរជាតិក្នុងការអនុវត្តលទ្ធកម្មសាធារណៈ ..................១៧

២.៦.បញ្ហាប្រឈមនៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈរបស់កម្ពុជា ................ ១៨

២.៧. ការសិក្សាសម្មតិកម្ម.................................................................................................. ១៨

២.៨. កំណែទម្រង់ និងគំនិតផ្តួចផ្តើមថ្មីៗ .............................................................................២៣

២.៩. ទិដ្ឋភាពសំខាន់ៗនៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃក្នុងលទ្ធកម្មសាធារណៈនៅកម្ពុជា...............................................................................................២៣

២.១០.សិក្សាពីប្រព័ន្ធលទ្ធកម្មសាធារណៈពីបណ្តាប្រទេសនៅអាស៊ាន........ ២៤

២.១១. ការរំលឹកវិធីសាស្ត្រស្រាវជ្រាវ ..................................................... ២៤
ជំពូកទី ៣ ..................................................... ២៦
សិក្សាពីការអនុវត្តលទ្ធកម្មសាធារណៈ ..................................................... ២៦
៣.១.សេចក្តីផ្តើម ..................................................... ២៦
៣.២.ក្របខ័ណ្ឌគតិយុត្ត ..................................................... ២៦
៣.៣.ទិដ្ឋភាពទូទៅ ..................................................... ២៦
៣.៤.ការអនុវត្តលទ្ធកម្មសាធារណៈរបស់រដ្ឋបាលខេត្តប៉ៃលិន សម្រាប់ឆ្នាំ ២០២១ ..................................................... ៣០
ជំពូកទី ៤ ..................................................... ៣២
វិធីសាស្ត្រស្រាវជ្រាវ ..................................................... ៣២
៤.១.សេចក្តីផ្តើម ..................................................... ៣២
៤.២. ប្រភេទនៃការវិភាគទិន្នន័យ ..................................................... ៣២
៤.៣ ទំហំសំណាក និងការជ្រើសរើសសំណាក ..................................................... ៣៣
៤.៤.ប្រភពទិន្នន័យ ..................................................... ៣៤
៤.៥.ឧបករណ៍ក្នុងការវិភាគទិន្នន័យ ..................................................... ៣៤
៤.៦.វិធីសាស្ត្រនៃការវិភាគទិន្នន័យ ..................................................... ៣៥
៤.៧.ភាពជឿជាក់នៃទិន្នន័យ ..................................................... ៣៥
ជំពូកទី ៥ ..................................................... ៣៧
ការវិភាគទិន្នន័យ ..................................................... ៣៧
៥.១.សេចក្តីផ្តើម ..................................................... ៣៧
៥.២. ព័ត៌មានទូទៅរបស់អ្នកផ្តល់សម្ភាសន៍ ..................................................... ៣៧
៥.៣.ការវាយតម្លៃលើទំនុកចិត្ត និងប្រសិទ្ធិភាព នៃអនុវត្តលទ្ធកម្ម សាធារណៈនៅរដ្ឋបាលខេត្តប៉ៃលិន ..................................................... ៤០
៥.៤.វិភាគផលប៉ះពាល់លើទំនុកចិត្ត និងប្រសិទ្ធិភាពនៃអនុវត្តលទ្ធកម្ម សាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅខេត្តប៉ៃលិន ..................................................... ៤០

**ជំពូកទី ៦** .................... ៤៤
**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** .................... ៤៤
**៦.១.សេចក្តីផ្តើម** .................... ៤៤
**៦.២ សង្ខេបលទ្ធផល** .................... ៤៥
**៦.៣ សេចក្តីសន្និដ្ឋាន** .................... ៤៥
**៦.៤ អនុសាសន៍** .................... ៤៥
**៦.៥ ដែនកំណត់ និងការស្រាវជ្រាវនាអនាគត** .................... ៤៦
**ឯកសារយោង** .................... ៤៧
**ឧបសម្ព័ន្ធ** .................... ៥០

# បញ្ជីតារាង

**តារាងទី១៖** តារាងទំនាក់ទំនងរវាងអថេរមិនឯករាជ្យ និងអថេរឯករាជ្យ .......................... **២៥**

**តារាងទី២៖** តារាងកម្រិតជឿជាក់នៃទិន្នន័យអាល់ហ្វា.................................................**៣៦**

**តារាងទី៣៖** តារាងអាល់ហ្វា (ភាពជឿជាក់នៃទិន្នន័យ)..............................................**៣៦**

**តារាងទី៤៖** មធ្យមភាគ និងបម្រែបម្រួលស្តង់ដានៃសម្មតិកម្ម........................................ **៤០**

**តារាងទី៥៖** ការវិភាគតាមសមីការ ......................................................................... **៤១**

# បញ្ជីក្រាហ្វិច និងដ្យាក្រាម

**ក្រាហ្វិចទី១៖** ទិន្នន័យភេទរបស់អ្នកផ្តល់សម្ភាសន៍.................................................. **៣៧**

**ក្រាហ្វិចទី២៖** ទិន្នន័យអាយុរបស់អ្នកផ្តល់សម្ភាសន៍.................................................. **៣៨**

**ដ្យាក្រាមទី៣៖** ទិន្នន័យកម្រិតសិក្សារបស់អ្នកផ្តល់សម្ភាសន៍ ........................................ **៣៩**

**ដ្យាក្រាមទី៤៖** ទិន្នន័យតួនាទីរបស់អ្នកផ្តល់សម្ភាសន៍................................................ **៣៩**

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១ សាវតានៃការសិក្សា

នៅឆ្នាំ២០២៣ នីតិកាលទី៧ នៃរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ឱ្យអនុវត្តនូវ "យុទ្ធសាស្រ្តបញ្ចកោណ" ដែលយុទ្ធសាស្រ្តនេះ បានបង្ហាញពីការបន្តអភិវឌ្ឍប្រទេសកម្ពុជាពី "យុទ្ធសាស្រ្តចតុកោណ" ហើយបង្ហាញពីចក្ខុវិស័យវែងឆ្ងាយនិងច្បាស់លាស់ក្នុងការអភិវឌ្ឍប្រទេសឱ្យកាន់តែរីកចម្រើនបន្ថែមទៀត។ យុទ្ធសាស្រ្តបញ្ចកោណនេះ បានបង្ហាញឱ្យឃើញពីការគិតគូលើសកម្មភាពអាទិភាពដែលរាជរដ្ឋាភិបាលកម្ពុជា ត្រូវយកចិត្តទុកដាក់ រួមមានបញ្ចកោណទី១៖ ការអភិវឌ្ឍន៍មូលធនមនុស្ស បញ្ចកោណទី២៖ ការធ្វើពិពិធកម្មសេដ្ឋកិច្ច បញ្ចកោណទី៣៖ ការអភិវឌ្ឍវិស័យឯកជន និងការងារ បញ្ចកោណទី៤៖ ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាប័ន្ន និងបញ្ចកោណទី៥៖ ការអភិវឌ្ឍ សេដ្ឋកិច្ច និងសង្គមឌីជីថល។ យុទ្ធសាស្រ្តបញ្ចកោណ-ដំណាក់កាលទី១ នេះ បានបន្តអនុវត្តនូវកម្មវិធីកែទម្រង់សំខាន់ៗ លើគ្រប់វិស័យ ក្នុងគោលដៅបម្រើឧត្តមប្រយោជន៍ជាតិ និងឆ្លើយតបទៅនឹងសំណូមពរនិងសេចក្តីត្រូវការរបស់ប្រជាជន។

តាមរយៈការដាក់ចេញនូវកម្មវិធីនយោបាយនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកតម្កើងជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរី និងសមធម៌សង្គម។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវយុទ្ធសាស្រ្តនានាជាច្រើន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របទៅតាមយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅ ជម្រុញលើកកម្ពស់ប្រសិទ្ធភាព និងពង្រឹងសមត្ថភាពការងារគ្រប់គ្រង និងការទទួលខុសត្រូវរបស់មន្រ្តីគ្រប់ជាន់ថ្នាក់ នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅគ្រប់ក្រសួង និងស្ថាប័នរហូតដល់ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ-សង្កាត់។ ជាមួយគ្នានេះ យុទ្ធសាស្រ្តនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨ - ២០២៥ ដែលមានគោលដៅកែប្រែជាជំហានៗនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ជាពិសេសឈានឆ្ពោះទៅរកការអនុវត្តថវិកាសមិទ្ធកម្មដែលជាយុទ្ធសាស្រ្តនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយនិងគណនេយ្យភាពសមិទ្ធកម្ម។

ទន្ទឹមនឹងនេះ ដើម្បីចូលរួមចំណែកសម្រេចបាននូវយុទ្ធសាស្រ្តនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨ - ២០២៥ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងឈានដល់

ការសម្រេចបាននូវយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ដែលជាយុទ្ធសាស្ត្រចាំបាច់ក្នុងការប្រែក្លាយប្រព័ន្ធលទ្ធកម្មសាធារណៈរបស់កម្ពុជា ឱ្យទៅជាប្រព័ន្ធមួយកាន់តែមានភាពជឿទុកចិត្ត តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព ការប្រកួតប្រជែង និងការសន្សំសំចៃ។

ការកែទម្រង់មជ្ឈការ និងវិសហមជ្ឈការ គឺជាផ្នែកមួយដ៏មានសារៈសំខាន់នៃក្របខ័ណ្ឌគោលនយោបាយដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន តាមរយៈការផ្ទេរសិទ្ធិអំណាច មុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងចាត់ចែង ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ តម្លាភាព និងគណនេយ្យភាព ត្រូវបានគាំទ្រដោយមានការកើនឡើងនៃ ឥទ្ធិពល និងជួរនៃ "អន្តរការីសង្គម" (ដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយ) ហើយពួកគេមានការគាំទ្រដោយការអាចរកបាននៃការបង្កើតទំនាក់ទំនងថ្មីតាមរយៈ ទូរស័ព្ទចល័ត អ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម (World Development Report, 2017)។ ស្របតាមសង្គមទំនើបនាសម័យកាលនេះ ការដឹកនាំតាមបែបប្រជាធិបតេយ្យទាមទារឱ្យអ្នកដឹកនាំត្រូវមាន គណនេយ្យភាព តម្លាភាព ដែលជាតុសំខាន់ទាំងពីរនេះចាំបាច់ត្រូវមាននៅក្នុងអភិបាលកិច្ចល្អ និងត្រូវធ្វើការបែងចែកធនធាន មនុស្ស និងហិរញ្ញវត្ថុអោយមានប្រសិទ្ធិភាព ស័ក្តសិទ្ធិភាព សុចរិតភាពក្នុងការអភិវឌ្ឍប្រទេសកាន់តែរីកចំរើនទៅមុខជាលំដាប់។

លើសពីនេះទៀត ការកែទម្រង់ប្រព័ន្ធថវិកា គឺជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ឈរលើមាគ៌ានៃការកែទម្រង់នេះ គោលដៅសំខាន់ គឺការធ្វើឱ្យប្រព័ន្ធថវិកាកាន់តែក្លាយទៅជា "ឧបករណ៍គោលនយោបាយ" ពិតប្រាកដក្នុងការវិភាគថវិកា សំដៅបង្កើនភាពជាម្ចាស់ និងគណនេយ្យភាពរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការប្រើប្រាស់ធនធានប្រកបដោយការសន្សំសំចៃ ប្រសិទ្ធិភាព និងស័ក្តសិទ្ធិភាព ក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការ សំណូមពរ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ។ ក្នុងក្របខណ្ឌនៃវគ្គថវិកាសំដៅលើកម្ពស់ប្រសិទ្ធិភាពនៃការអនុវត្តចំណាយ ទាមទារឱ្យក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអង្គភាពថវិកាទាំងអស់ត្រូវគោរពវិន័យថវិកា និងនីតិវិធីអនុវត្តចំណាយឆ្លងតាមលទ្ធកម្មសាធារណៈថផងដែរ។ (យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ)

ដោយសារលទ្ធកម្មសាធារណៈ គឺជាផ្នែកមួយដ៏សំខាន់នៃកែទម្រង់ប្រព័ន្ធថវិកា និងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលទាមទារឱ្យបង្កើនការយល់ដឹង និងសមត្ថភាពរបស់មន្ត្រីអនុវត្តឱ្យបានទូលំទូលាយនៅក្នុងរាជរដ្ឋាភិបាល សំដៅលើកកម្ពស់ការចូលរួម និងភាពជាម្ចាស់ពី

គ្រប់ ក្រសួង ស្ថាប័ន រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទាំងអស់ ដែលការអភិវឌ្ឍសមត្ថភាពជាកត្តាយ៉ាងសំខាន់។

បន្ថែមពីលើនេះទៀត ការត្រួតពិនិត្យឡើងវិញលើបញ្ហាប្រឈមនានាដែលកើតឡើងក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈនាពេលបច្ចុប្បន្ន កន្លងមកទោះបីមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីការដេញថ្លៃប្រកួតប្រជែង តាមរយៈសារព័ត៌មាន និងគេហទំព័រក៏ដោយ ក៏ចំនួនអ្នកចូលរួមដេញថ្លៃនៅមានកម្រិតនៅឡើយ ជាពិសេសការចូលរួមរបស់ប្រជាពលរដ្ឋ ក៏ដូចជាអ្នកដេញថ្លៃជាសហគ្រាសធុនមីក្រូ តូច និងមធ្យម។ ប្រជាពលរដ្ឋជាអ្នកដេញថ្លៃតាមរយៈសហគ្រាសធុនមីក្រូ តូច និងមធ្យម ជាសសរស្តម្ភសំខាន់នៃកំណើនសេដ្ឋកិច្ច បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ និងឧស្សាហូបនីយកម្មនៃសេដ្ឋកិច្ច។

## ១.២ ការថ្លែងបញ្ហា

តាមរយៈ ការផ្ទេរសិទ្ធិអំណាច និងមុខងារក្នុងការអនុវត្តលទ្ធកម្មសាធារណៈ ទៅអោយរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ជាច្រើនដំណាក់កាល និងមានភាពស្មុគស្មាញរួមមាន ការរៀបចំសេចក្តីព្រាងផែនការលទ្ធកម្ម, អនុវត្តកិច្ចលទ្ធកម្ម, កំណត់បុរេលក្ខណសម្បត្តិ, រៀបចំ ពិនិត្យ និងសម្រេចលើឯកសារដេញថ្លៃ, រៀបចំផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីការដេញថ្លៃ, ការទទួលសំណើរដេញថ្លៃ, ការប្រជុំបើកសំណើរដេញថ្លៃ, ការប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា, ត្រួតពិនិត្យ និងវាយតម្លៃលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃ, រៀបចំលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យាជូនអ្នកឈ្នះ និងអ្នកចាញ់, ផ្សព្វផ្សាយលទ្ធផល, ការរៀបចំសេចក្តីព្រាងកិច្ចសន្យា និងចុះហត្ថលេខាលើកិច្ចសន្យា, តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកិច្ចសន្យា។

ទន្ទឹមនឹងនេះផងដែរ ការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅតែមានគម្លាតធំ មិនទាន់សមស្របនៅឡើយ ជាពិសេសគម្លាតសមត្ថភាពពាក់ព័ន្ធចំណេះដឹង និងជំនាញគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន ជំនាញរដ្ឋបាលសម្រាប់អនុវត្តការងារប្រចាំថ្ងៃ និងជំនាញបច្ចេកទេសស្របតាមប្រភេទការងាររបស់មន្ត្រីម្នាក់ៗ។ មានន័យថាប្រសិទ្ធិភាពនៃការផ្តល់ និងគាំទ្រការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅទីស្តីការក្រសួងមហាផ្ទៃ ក៏ដូចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានអនុវត្តរហូតមកដល់ទល់ពេលនេះ នៅមិនទាន់ឆ្លើយទៅនឹងគម្លាតសមត្ថភាពមន្ត្រីរាជការនៅឡើយ។ តាមរយៈការចុះសម្ភាសន៍ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅទីស្តីការក្រសួងមហាផ្ទៃ ក៏ដូចជាមួយក្រុមប្រឹក្សា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ ក្រុង ស្រុក បានឱ្យដឹងថាស្ថានភាពធនធានមនុស្សនៅតាមអង្គភាពនីមួយៗមានបញ្ហាប្រហាក់ប្រហែលគ្នាគឺ

មន្ត្រីពុំមានសមត្ថភាព និងជំនាញសមស្រប ហើយភាគច្រើន មិនបានចូលរួមការបណ្តុះបណ្តាល និងមិនបានយល់ច្បាស់ពីតួនាទី ភារកិច្ចរបស់ខ្លួន ដែលកត្តាទាំងនេះបានធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធិភាពនៃការបំពេញការងាររបស់អង្គភាពនីមួយៗ (ផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៩ - ២០២៣)។ ពាក់ព័ន្ធនឹងចំណេះដឹង និងជំនាញបច្ចេកទេស លទ្ធកម្មសាធារណៈតម្រូវឱ្យឆ្លងកាត់វគ្គបណ្តុះបណ្តាលវិក្រឹតការរយៈពេលសមស្របមួយ មុននឹងទទួលការប្រគល់ភារកិច្ច និងការងារដល់មន្ត្រីរាជការសម្រាប់អនុវត្តផងដែរ។

ដើម្បីសម្រេចបានការអនុវត្តលទ្ធកម្មសាធារណៈស្របតាមផែនការលទ្ធកម្ម ប្រកបដោយសារប្រសិទ្ធភាព មន្ត្រីទទួលបន្ទុកអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវមានពង្រឹងសមត្ថភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ដើម្បីធានាថាគ្រប់សកម្មភាពដែលបានអនុវត្ត ដើម្បីបម្រើផលប្រយោជន៍ដល់សង្គម។ ដោយមានការកើនឡើងអំពីព្រួយបារម្ភជុំវិញការអនុវត្តការងារ និងការទទួលខុសត្រូវខ្ពស់ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានភារកិច្ចផ្តល់សេវាកម្ម បង្កើន និងពង្រឹងគោលនយោបាយ សេចក្តីសម្រេច និងការអនុវត្តផ្ទាល់ប្រកដដោយការទទួលខុសត្រូវ។ កត្តាចង្អុលបង្ហាញអំពីការបំពេញភារកិច្ចភាគច្រើនបានផ្តោតលើធនធានមនុស្ស ហើយមានផលវិបាកក្នុងការស្វែងរកប្រភពព័ត៌មានគ្រប់គ្រាន់ សម្រាប់បង្ហាញពីគុណភាពនៃការអនុវត្តនីតិវិធីដែលបង្កើតឡើង និងការយល់ដឹងបន្ថែមពីចំណុចខ្លាំង និងចំណុចខ្សោយ នៃការបំពេញមុខងាររបស់មន្ត្រីក្នុងមូលដ្ឋាន។ យើងបានសង្កេតឃើញថា ប្រជាពលរដ្ឋនៅមិនទាន់ទទួលបាននូវសេចក្តីលម្អិត និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនៅឡើយទេ ហើយក្នុងកត្តានេះផងដែរ ការសិក្សានេះចង់បង្ហាញឱ្យឃើញថា អង្គការក្រៅរដ្ឋាភិបាល និងប្រជាពលរដ្ឋមិនទាន់មានទំនុកចិត្ត និងការទទួលបាននូវភាពកក់ក្តៅពេញលេញពីសំណាក់រាជរដ្ឋាភិបាលតាមរយៈរដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយទេ ដែលបណ្តាលឱ្យមានការមិនពេញចិត្តទៅលើការអនុវត្តលទ្ធកម្មសាធារណៈ (Daniel Pye, 2014, Global Fund’s probe saw little cooperation, The Phnom Penh Post.) ។ ម្យ៉ាងវិញទៀតក៏មានបញ្ហាមួយចំនួនទាក់ទងនឹងស្ថានភាព សកម្មភាព និងបញ្ហាអំពើពុករលួយ រវាងស្ថាប័នរដ្ឋ និងរដ្ឋ ដែលរងជះឥទ្ធពលមិនល្អដល់ប្រសិទ្ធិភាព ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសដោយផ្តោតទៅលើការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈទាំងមូលតែម្តង (អង្គការទិន្នន័យអំពីការអភិវឌ្ឍ, ២០១៥, ,(ODC))។ ដើម្បីធានាឱ្យបាននូវការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយ តម្លាភាព គណនេយ្យភាព ការប្រកួតប្រជែង ការសន្សំសំចៃ និងការជឿទុកចិត្តបានពីសំណាក់ប្រជាពលរដ្ឋ

អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល ទាមទារការចូលរួមពីប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ស្វែងរកចំណុចខ្វះ និងការបកស្រាយពន្យល់បន្ថែម ជាកាតព្វកិច្ចរួមក្នុងមូលដ្ឋាន។

## ១.៣ សំណួរស្រាវជ្រាវ

១.តើការយល់ដឹងនិងសមត្ថភាពរបស់មន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានផលប៉ះពាល់ទៅលើប្រសិទ្ធិភាព និងទំនុកចិត្តលើការអនុវត្តកិច្ចលទ្ធកម្មដែរឬទេ ?

២.តើការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន ទទួលបានតម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែងដែរឬទេ ?

៣. តើការដេញថ្លៃទំនិញ និងសេវាកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិនមានការសន្សំសំចៃដែរឬទេ ?

## ១.៤ គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះមានដូចខាងក្រោម៖

- វាយតម្លៃការយល់ដឹងនិងសមត្ថភាពរបស់មន្ត្រីក្នុងអនុវត្តកិច្ចលទ្ធកម្ម នៅរដ្ឋបាលថ្នាក់ក្រោមក្នុងមូលដ្ឋានខេត្តប៉ៃលិន
- វាយតម្លៃប្រសិទ្ធិភាពនៃការសន្សំសំចៃក្នុងការអភិវឌ្ឍខេត្តប៉ៃលិន
- វាយតម្លៃ តម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែង ក្នុងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលខេត្តប៉ៃលិន
- ទាញសេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.៥ ការតាងសម្មតិកម្ម

នៅក្នុងការសិក្សាស្រាវជ្រាវមួយយើងត្រូវបែងចែកឱ្យដាច់រវាងអថេរពីរគឺ អថេរឯករាជ្យ និងអថេរពឹងផ្អែក។ ដោយអថេរទាំងពីរ នេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវ និងអាចនាំឱ្យការសិក្សាស្រាវជ្រាវមានភាពច្បាស់លាស់ជាងមុន និងងាយស្រួលក្នុងការប្រមូលឯកសារនិងទិន្នន័យជាពិសេសការរៀបចំកម្រងសំណួរនៃប្រធានបទនីមួយៗ នៅក្នុងការតាងរបស់អថេរឯករាជ្យ និងអថេរពឹងផ្អែក បានធ្វើអោយយើងទាញបាននូវសម្មតិកម្មសំខាន់ចំនួន ០៤ ដូចខាងក្រោមនេះ៖

សម្មតិកម្មសូន្យទី១ ៖ការយល់ដឹង និងសមត្ថភាពរបស់មន្ត្រី មិនមានផលប៉ះពាល់ជាវិជ្ជមាន និងសារៈសំខាន់ទៅលើ ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តកិច្ចលទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន។

សម្មតិកម្មសូន្យទី២ ៖ការសន្សំសំចៃ មិនមានផលប៉ះពាល់ជាវិជ្ជមាន និងសារៈសំខាន់ទៅលើ ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តកិច្ចលទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន។

សម្មតិកម្មសូន្យទី៣ ៖តម្លាភាព និងគណនេយ្យភាព មិនមានផលប៉ះពាល់ជាវិជ្ជមាន និងសារៈសំខាន់ទៅលើ ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តកិច្ចលទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន

សម្មតិកម្មសូន្យទី៤ ៖ការប្រកួតប្រជែង មិនមានផលប៉ះពាល់ជាវិជ្ជមាន និងសារៈសំខាន់ទៅលើ ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តកិច្ចលទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន

## ១.៦ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវចំពោះប្រធានបទ "កត្តាកំណត់ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់រដ្ឋបាលខេត្តប៉ៃលិន" គឺផ្តោតសំខាន់ទៅលើចំណេះដឹង និងការយល់ដឹងរបស់មន្ត្រីទទួលបន្ទុកអនុវត្ត ប្រសិទ្ធិភាព ស័ក្តសិទ្ធិភាព ការសន្សំសំចៃ តម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែងក្នុងដំណើរការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់រដ្ឋបាលខេត្តប៉ៃលិន ។

## ១.៧ សារៈសំខាន់នៃការស្រាវជ្រាវ

នៅក្នុងដំណើរនៃការអនុវត្តលទ្ធកម្មសាធារណៈ គឺជួយជម្រុញឱ្យការអភិវឌ្ឍប្រទេសជាតិមានប្រសិទ្ធភាពក៏ដូចជា ជ្រោមជ្រែងដល់ការសន្សំសំចៃរបស់ក្រសួង ស្ថាប័នរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រកបដោយវិជ្ជាជីវៈ តម្លាភាព គណនេយ្យភាព ប្រសិទ្ធិភាព ចីរភាព និងប្រយោជន៍សាធារណៈជាចម្បង។ ខ្លឹមសារនៃនិក្ខេបបទនេះ នឹងបង្ហាញដល់អ្នកអានពីទស្សនទានកត្តាកំណត់ទំនុកចិត្ត និងប្រសិទ្ធិភាពនៃការអនុវត្តលទ្ធកម្មសាធារណៈក្នុងការអភិវឌ្ឍមូលដ្ឋានក្នុងខេត្តប៉ៃលិន និងឱកាសដែលអាចឱ្យប្រជាពលរដ្ឋចូលរួមយ៉ាងសកម្មជាមួយរដ្ឋ ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ ក្នុងការកសាងសង្គមកម្ពុជាយើងឱ្យក្លាយទៅជាសង្គមមួយប្រកបដោយបរិយាប័នបាន។ លើសនេះទៀត ការសិក្សាស្រាវជ្រាវនេះក្នុងទិសដៅនេះពិតជាបានពង្រឹងនូវចំណេះដឹងដែលមានស្រាប់ឱ្យកាន់តែប្រសើរឡើងថែមទៀតទៅលើប្រធានបទនេះ។ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះគឺកំណត់អត្តសញ្ញាណ និងគូសបញ្ជាក់អំពីបញ្ហាផ្សេងក្នុងវិស័យគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាការពង្រឹងសមត្ថភាពមន្ត្រីរាជការ ចូលរួមចំណែកដោះស្រាយសមស្រប ការសន្សំសំចៃចំណាយ ក្នុងការអភិឌ្ឍមូលដ្ឋានឱ្យកាន់តែល្អប្រសើរ។ លទ្ធផលដែលទទួលបានមកពី

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងផ្តល់ជាធាតុចូលក្នុងគោលការណ៍ណែនាំសម្រាប់គោលនយោបាយសេដ្ឋកិច្ចជារួម និងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឱ្យកាន់តែមានតម្លាភាព, គណនេយ្យភាព, សុចរិតភាព, ការប្រកួតប្រជែង, ភាពយុត្តិធម៌, ប្រសិទ្ធិភាព, ស័ក្តិសិទ្ធិភាព, ចីរភាព, គុណភាព, ការសន្សំសំចៃ, និងទាន់ពេលវេលា នាពេលអនាគតគ្រប់វិស័យសាធារណៈ និងឯកជន តាមរយៈរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រៅពីនេះទៀតសព្វថ្ងៃនេះការគ្រប់គ្រងនៅមូលដ្ឋានថ្នាក់ក្រោមជាតិ ព្រមទាំងអង្គភាពសាធារណៈ គ្រឹះស្ថានសាធារណៈ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន មានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងចំពោះការអនុវត្តនីតិវិធីកិច្ចលទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមតាមរយៈការដេញថ្លៃទំនិញ និងសេវាកម្ម។ ការបម្រើជូនប្រជាពលរដ្ឋដោយអភិបាលកិច្ចល្អតាមរយៈការគ្រប់គ្រងហិរញ្ញវត្ថុដ៏មានប្រសិទ្ធិភាពល្អក្នុងការចំណាយចំគោលដៅ មិនត្រឹមតែគាំទ្រដល់ការផ្សព្វផ្សាយប៉ុណ្ណោះទេ ថែមទាំងតាមរយៈការបង្កើតនៃប្រាក់ចំណូលសេដ្ឋកិច្ចគ្រួសារក៏ដូចជាចំណូលរបស់រដ្ឋតាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ប្រព័ន្ធធារាស្ត្រ អគារ សាលារៀន មន្ទីរពេទ្យ នៅថ្នាក់មូលដ្ឋានក្នុងខេត្តប៉ៃលិន។ ដូច្នេះ វិស័យរដ្ឋបាលសាធារណៈតាមរយៈកម្មវិធីកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈពិតជាមានសារៈសំខាន់ និងប្រាស្រ័យទៅលើការអនុវត្តរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការសិក្សាទៅកត្តាកំណត់អត្តសញ្ញាណ នៃគុណភាព ប្រសិទ្ធិភាព ក្នុងការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន ជាការពិចារណាយ៉ាងសំខាន់ក្នុងអង្គភាព និងផែនការអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ចពិតប្រាកដណាស់។ គុណភាពទំនិញ និងសេវាកម្ម ទទួលបានតាមរយៈកិច្ចលទ្ធកម្ម ការដេញថ្លៃប្រកួតប្រជែង ប្រកបដោយតម្លាភាព គណនេយ្យភាព ភាពយុត្តិធម៌ និងការសន្សំសំចៃ គឺជាកត្តាដ៏សំខាន់ក្នុងការសម្រេចចិត្ត និងការឆ្លុះបញ្ចាំងពីអភិបាលកិច្ចល្អ ការគ្រប់គ្រងសាច់ប្រាក់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋពេញដោយទំនុកចិត្ត របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្លើយតបទៅនឹងគោលនយោបាយថ្នាក់ជាតិ និង"យុទ្ធសាស្ត្របញ្ចកោណ" របស់រាជរដ្ឋាភិបាល។ សរុបរួមមកផលប្រយោជន៍ខាងលើនេះពិតជាបានជួយរំលឹកដល់អ្នកធ្វើផែនការ អ្នកលើកគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គម្រោងហិរញ្ញវត្ថុ អ្នកផ្តល់សេវាសាធារណៈ និងអ្នកសម្រេចចិត្តខាងគោលនយោបាយដែលពាក់ព័ន្ធ ត្រូវស្វែងយល់អំពីសារៈសំខាន់ទាក់ទងទៅគុណភាពទំនិញសេវាកម្ម និងអភិបាលកិច្ចល្អតាមរយៈកិច្ចលទ្ធកម្មប្រកបដោយប្រសិទ្ធិភាព។

ដូច្នេះហើយក្នុងបរិបទនេះដោយការសិក្សាទៅការយល់ដឹងរបស់មន្ត្រីក្នុងរដ្ឋបាលខេត្តប៉ៃលិន និងការកំណត់នៃប្រសិទ្ធិភាពចំណាយលើការសន្សំសំចៃ ការបើកចំហព័ត៌មានពាក់ព័ន្ធលទ្ធកម្មសម្រាប់សាធារណជន ប្រជាពលរដ្ឋ ងាយស្រួលយល់ ងាយស្រួលទទួលបានទាន់ពេលវេលា

ប្រកបដោយគណនេយ្យភាព ការប្រកួតប្រជែងដ៏យុត្តិធម៌ពិតជាដើរតួនាទីយ៉ាងសំខាន់សម្រាប់អភិវឌ្ឍ និងសេដ្ឋកិច្ចមូលដ្ឋានក្នុងខេត្តប៉ៃលិន។

## ១.៨ ប្លង់នៃការសិក្សា

**ជំពូកទី ១៖** គោលបំណងនៃជំពូកនេះគឺជាព័ត៌មានណែនាំរួមមាន សាវតានៃការសិក្សា ការថ្លែងបញ្ហា គោលបំណងនៃការសិក្សាស្រាវជ្រាវ សំណួរសិក្សាស្រាវជ្រាវ ទំហំនិងដែនកំណត់នៃការសិក្សា សារៈសំខាន់នៃការសិក្សា ប្លង់នៃការនៃការសិក្សាទាក់ទងនឹងប្រធានបទ កត្តាកំណត់ទំនុកចិត្ត និងប្រសិទ្ធិភាពនៃអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈនៅរដ្ឋបាលខេត្តប៉ៃលិន។

**ជំពូកទី ២៖** គោលបំណងនៃជំពូកនេះ គឺដើម្បីពិនិត្យឡើងវិញនូវទ្រឹស្តីដែលទាក់ទងនឹងប្រធានបទ នៃការសិក្សាស្រាវជ្រាវ។ នៅក្នុងជំពូកនេះ រួមមាន ពាក្យគន្លឹះ ក្របខ័ណ្ឌទ្រឹស្តីនៃលទ្ធកម្មសារធារណៈ ក្របខ័ណ្ឌទ្រឹស្តីនៃលទ្ធកម្មសារធារណៈនៅកម្ពុជា ឧត្តមានុវត្តន៍អន្តរជាតិក្នុងការអនុវត្តលទ្ធកម្មសាធារណៈ បញ្ហាប្រឈមក្នុងការអនុវត្តលទ្ធកម្មសាធារណៈរបស់កម្ពុជា កំណែទម្រង់ និងគំនិតផ្តួចផ្តើមថ្មីៗ ទិដ្ឋភាពសំខាន់ៗនៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃក្នុងលទ្ធកម្មសាធារណៈ ការសិក្សាពីប្រព័ន្ធលទ្ធកម្មសាធារណៈពីបណ្តាប្រទេសនៅអាស៊ាន និងការរំលឹកវិធីសាស្រ្តស្រាវជ្រាវ។

**ជំពូកទី ៣៖** គោលបំណងនៃជំពូកនេះគឺដើម្បីបង្ហាញអំពីការអនុវត្តលទ្ធកម្មសាធារណៈរួមមានក្របខ័ណ្ឌគតិយុត្ត ទិដ្ឋភាពទូទៅ យន្តការ និងនីតិវិធីនៃការអនុវត្តលទ្ធកម្មសាធារណៈ វិធីសាស្រ្តលទ្ធកម្មសាធារណៈ និងការអនុវត្តលទ្ធកម្មសាធារណរបស់រដ្ឋបាលខេត្តប៉ៃលិនសម្រាប់ឆ្នាំ ២០២១។

**ជំពូកទី ៤៖** គោលបំណងនៃជំពូកនេះគឺដើម្បីពន្យល់ពីវិធីសាស្រ្តដែលត្រូវបានប្រើក្នុងការសិក្សាបច្ចុប្បន្ន។ សម្រាប់គោលបំណងនៃជំពូកនេះត្រូវបានចែកជា ៧ ផ្នែក។ ផ្នែកទី១ ការជ្រើសរើសសំណាក និងប៉ាន់គំរូ ផ្នែកទី២ ប្រភេទ និងប្រភពទិន្នន័យ ផ្នែកទី៣ ឧបករណ៍ក្នុងការវិភាគទិន្នន័យ ផ្នែកទី៤ វិធីសាស្រ្តក្នុងការជ្រើសរើសគំរូ ផ្នែកទី ៥ នីតិវិធីនៃការប្រមូលទិន្នន័យ នៅផ្នែកទី ៦ ភាពជឿកជាក់នៃទិន្នន័យ។

**ជំពូកទី ៥៖** គោលបំណងនៃជំពូកនេះ គឺដើម្បីធ្វើការវិភាគទៅលើទិន្នន័យដែលបានប្រមូល។ ដោយជំពូកនេះ ត្រូវបានបែងចែកជា ៣ ផ្នែកសំខាន់ៗ រួមមាន ផ្នែកទី១ ព័ត៌មានទូទៅរបស់អ្នកផ្តល់សម្ភាសន៍, ផ្នែកទី២ ការវាយតម្លៃកត្តាកំណត់ទំនុកចិត្តដល់ការអនុវត្តលទ្ធកម្មសាធារណៈ

នៅរដ្ឋបាលខេត្តប៉ៃលិន និងផ្នែកទី៣ ប្រសិទ្ធិភាពនៃការអនុវត្តលទ្ធកម្មសាធារណៈនៅរដ្ឋបាលខេត្តប៉ៃលិន។

**ជំពូកទី ៦៖** ជំពូកនេះផ្តោតទៅលើការសង្ខេបដើម្បីកំណត់នូវចំណុចសំខាន់ៗនៃការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ នៅរដ្ឋបាលខេត្តប៉ៃលិន សង្ខេបលទ្ធផលដែលបានរកឃើញ សេចក្តីសន្និដ្ឋាន អនុសាសន៍ និងការស្រាវជ្រាវអនាគត។

# ជំពូកទី២៖ ការរំលឹកទ្រឹស្តី

## ២.១. សេចក្តីផ្តើម

យោងតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈនៅកម្ពុជា លទ្ធកម្មសំដៅដល់ការទិញ ឬការរកបាននូវទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាតាមរយៈវិធីសាស្ត្រដែលមានចែងនៅក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ ចំពោះលទ្ធកម្មសាធារណៈ សំដៅដល់កិច្ចលទ្ធកម្មដែលធ្វើឡើងដោយស្ថាប័នអនុវត្តលទ្ធកម្ម/ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ។

លទ្ធកម្មសាធារណៈ គឺជាបទប្បញ្ញត្តិនៃគោលការណ៍ វិធាន និងនីតិវិធីដែលបានអនុវត្តចំពោះរដ្ឋនានា ដើម្បីអនុវត្តដំណើរការប្រកបដោយប្រសិទ្ធភាពនៅពេលទទួលបានទំនិញ សេវាកម្ម ឬការងារ និងអនុវត្តតាមគោលបំណងគោលនយោបាយរបស់ខ្លួន។ ច្បាប់លទ្ធកម្មសាធារណៈនីមួយៗត្រូវវិភាគដោយអនុលោមតាមលក្ខខណ្ឌនៃ រដ្ឋ ឬអង្គការអន្តរជាតិជាក់លាក់។ ( Arciniegas Parra Juan David, 2024)

លទ្ធកម្មសាធារណៈ មានន័យថា ជាការប្រើមូលនិធិសាធារណៈដើម្បីទទួលបានទំនិញ និងសេវាកម្មដែលត្រូវការ ដើម្បីបំពេញតម្រូវការជាក់លាក់ទាំងបរិមាណ គុណភាព និងតម្លៃ។ លទ្ធកម្មសាធារណៈ គឺជាធាតុផ្សំជាមូលដ្ឋាននៃការផ្តល់សេវាសាធារណៈ ដែលរដ្ឋាភិបាលត្រូវមានរបស់គ្រប់គ្រងការទិញទំនិញ សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការសម្រាប់ប្រតិបត្តិការរបស់សង្គមជាតិទាំងមូល។ នៅទូទាំងពិភពលោក លទ្ធកម្មសាធារណៈជាផ្នែកមួយសំខាន់នៃការចំណាយរបស់រដ្ឋាភិបាល និងជាកត្តាជំរុញកំណើនសេដ្ឋកិច្ច ព្រមទាំងការចូលរួមអភិវឌ្ឍន៍ប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ។ (ធនាគារអភិវឌ្ឍអាស៊ី ឆ្នាំ២០១៧)

លទ្ធកម្មសាធារណៈសំដៅទៅលើការទិញទំនិញ សេវាកម្ម និងសេវាទីប្រឹក្សារបស់រាជរដ្ឋាភិបាល និងសហគ្រាសសាធារណៈរបស់រដ្ឋ។ វាជាសរស្តដ៏មានសារៈសំខាន់នៃការផ្តល់សេវាកម្មសម្រាប់រាជរដ្ឋាភិបាល ម្យ៉ាងវិញទៀត លទ្ធកម្មសាធារណៈជាប្រភពចំណូលនៃការប្រមូលពន្ធនៃអ្នកជាប់ពន្ធដែរ រដ្ឋាភិបាលត្រូវរំពឹងថានឹងអនុវត្តឱ្យមានប្រសិទ្ធិភាព ជាមួយនឹងស្តង់ដាខ្ពស់នៃសុចរិតភាព ដើម្បីធានាបាននូវគុណភាពនៃសេវាកម្ម និងការការពារផលប្រយោជន៍សាធារណៈ។ ( OECD (2021)

លទ្ធកម្មសាធារណៈ សំដៅលើដំណើរការដែលអាជ្ញាធរសាធារណៈ សេនាធិការរបស់រដ្ឋាភិបាល ឬអាជ្ញាធរមូលដ្ឋានក្នុងការបញ្ជា ទិញទំនិញ ឬសេវាកម្មពីអ្នកផ្គត់ផ្គង់។ វិសាលភាពនៃទំនិញ និងសេវាកម្មដែលបានបញ្ជាទិញដោយអាជ្ញាធរសាធារណៈមានភាពទូលំទូលាយ ចាប់ពីហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ និងគម្រោងអភិវឌ្ឍទីក្រុង រហូតដល់ការដាក់ឱ្យប្រើប្រាស់នូវសេវាសាធារណៈសំខាន់ៗក្នុងវិស័យថែទាំសុខភាព និងសង្គម និង ទិញទំនិញទូទៅដូចជា សម្ភារៈការិយាល័យ

គ្រឿងសង្ហារឹម និងគ្រឿងឧបភោគបរិភោគ។ (National Action Plans on Business and Human Rights , 2024)។

នៅក្នុងអង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ (OECD) កិច្ចសន្យាលទ្ធកម្មសាធារណៈមានចំនួន 12,9% នៃផលិតផលក្នុងស្រុកសរុបជាមធ្យម ហើយជាធាតុផ្សំដ៏សំខាន់នៃសេដ្ឋកិច្ចទាំងមូល។ លទ្ធកម្មសាធារណៈអាចជាប្រភពចំណូលដ៏សំខាន់បំផុតតែមួយគត់នៅក្នុងវិស័យមួយចំនួន រួមទាំងវិស័យសុខភាព និងការស្រាវជ្រាវ ដែលទាក់ទងនឹងឧស្សាហកម្មសំណង់ និងការដឹកជញ្ជូន។

ជារួមមកលទ្ធកម្មសាធារណៈបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការចំណាយរបស់រាជរដ្ឋាភិបាល ប្រកបដោយប្រសិទ្ធភាព និងតម្លាភាពដោយអនុវត្តតាមនីតិវិធីលទ្ធកម្មក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់ប្រទេស។ ជំពូកទី២ ការរំលឹកទ្រឹស្តីនេះ ធ្វើការពិនិត្យលម្អិតលទ្ធកម្មសាធារណៈ ពាក្យគន្លឹះសំខាន់ៗមាននៅក្នុងលទ្ធកម្មសាធារណៈរបស់ប្រទេសកម្ពុជាស្របតាមឧត្តមានុវត្តអន្តរជាតិ។

## ២.២ ពាក្យគន្លឹះ

ការស្វែងយល់ពីកត្តាកំណត់ទំនុកចិត្ត និងប្រសិទ្ធិភាពលើប្រព័ន្ធលទ្ធកម្មសាធារណៈ គឺផ្តោតសំខាន់ លើគ្រប់ទិដ្ឋភាព រួមទាំងសមត្ថភាព ចំណេះដឹង គុណភាពទំនិញ សេវាកម្មការបើកចំហព័ត៌មានដេញថ្លៃ ភាពងាយស្រួលទទួលបានព័ត៌មានអំពីលទ្ធកម្ម ការសន្សំសំចៃ ការប្រកួតប្រជែងនិងភាពយុត្តិធម៌។ កត្តាកំណត់ទំនុកចិត្តលើប្រព័ន្ធលទ្ធកម្មសាធារណៈរបស់ប្រជាពលរដ្ឋ និងអ្នកចូលរួមដេញថ្លៃ គឺជាការវាស់វែងដ៏សំខាន់នៃការអនុវត្តរបស់រាជរដ្ឋាភិបាល និងជាកត្តាជំរុញដ៏សំខាន់នៃការជឿទុកចិត្តលើអភិបាលកិច្ចល្អ។

ដើម្បីឈានទៅរកការសិក្សាស្រាវជ្រាវលម្អិតបន្ថែមពាក់ព័ន្ធនឹងប្រធានបទនេះ ពាក្យគន្លឹះសំខាន់ៗត្រូវបានពន្យល់ ដើម្បីដើរតួជាផ្នែកមួយនៃលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃទៅលើប្រធានបទនេះ។

| វាក្យស័ព្ទ | និយមន័យ | ការរំលឹកស្នាដៃ |
|---|---|---|
| សមត្ថភាព និងការយល់ដឹងរបស់មន្ត្រី | សមត្ថភាព និងការយល់ដឹងរបស់មន្ត្រីសំដៅលើការងារក្នុងកិច្ចការកិច្ចលទ្ធកម្មសាធារណៈ គឺជាមនុស្សដែលចូលរួមក្នុងការធ្វើផែនការ ដឹកនាំ និងអនុវត្តលទ្ធកម្មសាធារ | World Bank, (2015), The Public Procurement Laws. |

| | | |
|---|---|---|
| | ណៈ មានបទពិសោធន៍ និងការវៃឆ្លាត ព្រមទាំងគោរពតាមលក្ខខណ្ឌនៃច្បាប់កំណត់ ។ | |
| ការសន្សំសំចៃ | ការសន្សំសំចៃ សំដៅដល់ការប្រើប្រាស់ថវិកាសមស្របបំផុតក្នុងចំណាយ ដែលក្នុងនោះត្រូវពិចារណាផងដែរលើកត្តាពាក់ព័ន្ធនានាក្នុងការអនុវត្តនីតិវិធីលទ្ធកម្មដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ឬអ្នកទទួលការ។<br><br>ការសន្សំសំចៃ សំដៅដល់ការទទួលបានអត្ថប្រយោជន៍ដ៏ល្អប្រសើរតាមរយៈការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធភាព និងសេដ្ឋកិច្ច ដោយការអនុវត្តគោលការណ៍លទ្ធកម្មស្នូល និងការពិចារណាដែលពាក់ព័ន្ធ ដែលអាចរាប់បញ្ចូលទាំងការចំណាយលើវដ្តជីវិត និងគោលបំណងអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងបរិស្ថាន ។<br><br>ការសន្សំសំចៃ មានន័យថាការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធភាព និងសេដ្ឋកិច្ច ដែលតម្រូវឱ្យមានការវាយតម្លៃលើការចំណាយ និងអត្ថប្រយោជន៍ដែលពាក់ព័ន្ធ រួមជាមួយនឹងការវាយតម្លៃហានិភ័យ និងលក្ខណៈមិនមានតម្លៃ និង/ឬការចំណាយលើវដ្តជីវិតតាមការសមស្រប។<br><br>ការសន្សំសំចៃ សំដៅដល់ការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធភាព សន្សំសំចៃ និងក្រមសីលធម៌ ដែលមិនស្របតាមគោលនយោបាយ | ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០២៣<br><br>Asian Development Bank (2017), ADB Procurement Policy.<br><br>World Bank (2017), Procurement in IPF and Other Operational Procurement Matters.<br><br>Australian Government. (2024), Commonwealth Procurement Rules. |

| | | |
|---|---|---|
| | របស់ Commonwealth។ សម្របសម្រួលការសម្រេចចិត្តប្រកបដោយគណនេយ្យភាព និងតម្លាភាព។ លើកទឹកចិត្តឱ្យមានការចូលរួមសមស្របជាមួយនឹងហានិភ័យ; និងត្រូវស្របទៅតាមទំហំ និងវិសាលភាពនៃតម្រូវការអាជីវកម្ម។ | |
| តម្លាភាព និង គណនេយ្យភាព | តម្លាភាព សំដៅដល់ការទទួលបានព័ត៌មានដែលពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈដោយចំហ និងសិទ្ធិចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មសាធារណៈ។ | ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០២៣ |
| | តម្លាភាពក្នុងលទ្ធកម្មកើតឡើងក្នុងការអនុវត្តផ្សេងៗគ្នា ដូចជា៖ ការផ្សព្វផ្សាយគោលនយោបាយលទ្ធកម្ម។ ការបោះពុម្ពផ្សាយជាមុននៃផែនការលទ្ធកម្ម; ការផ្សព្វផ្សាយសេចក្តីជូនដំណឹងដេញថ្លៃ; ការបង្ហាញលក្ខណៈវិនិច្ឆ័យវាយតម្លៃនៅក្នុងឯកសារស្នើសុំ; ការបោះពុម្ពផ្សាយកិច្ចសន្យា និងតម្លៃដែលបានបង់; បង្កើតយន្តការបណ្តឹង/តវ៉ា/វិវាទដែលសមស្រប និងទាន់ពេលវេលា។ ការអនុវត្តលក្ខខណ្ឌនៃការបង្ហាញហិរញ្ញវត្ថុ និងជម្លោះផលប្រយោជន៍សម្រាប់មន្ត្រីលទ្ធកម្មសាធារណៈ។ និងការបោះពុម្ពផ្សាយបញ្ជីទណ្ឌកម្មអ្នកផ្គត់ផ្គង់។ | UNDP (2012), Transparency and public procurement. |
| | តម្លាភាព សំដៅដល់ការរកបាននូវព័ត៌មានដែលអាចជាក់ទុកចិត្តបាន ពាក់ព័ន្ធ និងទាន់ពេលវេលាអំពីការរៀបចំស្ថាប័នសម្រាប់ | |

| | | |
|---|---|---|
| | កិច្ចលទ្ធកម្ម និងអនុញ្ញាតិឱ្យមានការវាយតម្លៃអំពីស្ថានភាពហិរញ្ញវត្ថុ របស់រដ្ឋាភិបាល និងតម្លៃពិតប្រាកដ អត្ថប្រយោជន៍នៃសកម្មភាពរបស់រដ្ឋាភិបាល។ តម្លាភាព គឺជាមធ្យាបាយពង្រឹងអភិបាលកិច្ចល្អផងដែរ។ ដើម្បីសម្រេចបាននូវភាពប្រសើរឡើងនៃគណនេយ្យភាព និងការអនុវត្តរបស់រាជរដ្ឋាភិបាលប្រកដដោយតម្លាភាព ទាមទារឱ្យមានការចូលរួមសហការពីភាគីវិស័យឯកជន និងវិស័យសាធារណៈដើម្បីផ្តល់ជាតុចូល ក៏ដូចជាព័ត៌មានជាក់លាស់សម្រាប់អនុវត្តគោលនយោបាយសាធារណៈ។ <br><br> តម្លាភាពមានន័យថា ការជានាតាមរយៈឯកសារសមស្រប និងការពិនិត្យឡើងវិញនៃសកម្មភាពក្នុងដំណើរការលទ្ធកម្ម ថា ១) ព័ត៌មានអំពីលទ្ធកម្មដែលពាក់ព័ន្ធត្រូវបានបង្ហាញជាសាធារណៈដល់ភាគីដែលចាប់អារម្មណ៍ ក្នុងលក្ខណៈស្រប និងទាន់ពេលវេលា តាមរយៈប្រភពដែលអាចចូលប្រើបាន និងទូលំទូលាយ(ឬសមហេតុផល) ការចំណាយ; ២) ការរាយការណ៍សមស្របនៃសកម្មភាពលទ្ធកម្ម; និង ៣) ការប្រើប្រាស់បទប្បញ្ញត្តិរក្សាការសម្ងាត់ក្នុងកិច្ចសន្យាតែក្នុងករណីដែលត្រឹមត្រូវប៉ុណ្ណោះ។ <br><br> គណនេយ្យភាព សំដៅដល់ការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងការធ្វើ | World Bank (2015), Transparency in Public Finance. <br><br> Asian Development Bank (2017), ADB Procurement Policy. |

| | | |
|---|---|---|
| | សេចក្ដីសម្រេច និងចាត់វិធានការក្នុងអំឡុងដំណើរការលទ្ធកម្មសាធារណៈ។<br><br>គណនេយ្យភាព មានន័យថាជាការអនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការ និងការអនុវត្តសេចក្ដីសម្រេចចិត្ត ហើយទទួលខុសត្រូវ ចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍ព្រមទាំងបញ្ជាក់ពីមូលហេតុ នូវអ្វីដែលខ្លួនបានសម្រេច និងអនុវត្ត។ មិនត្រឹមតែជាការទទួលខុសត្រូវចំពោះនរណាម្នាក់ដែលបានស្នើឱ្យធ្វើអ្វីមួយនោះទេ ប៉ុន្តែជាការទទួលខុសត្រូវនូវសកម្មភាពដែលបានអនុវត្តចំពោះមុខអ្នកពាក់ព័ន្ធទាំងអស់ផងដែរ។<br><br>គណនេយ្យភាព មានន័យថា មន្ត្រីទទួលខុសត្រូវចំពោះសកម្មភាព និងការសម្រេចចិត្តដែលខ្លួនអនុវត្តទាក់ទងនឹងលទ្ធកម្ម និងសម្រាប់លទ្ធផលលទ្ធផល។<br><br>គណនេយ្យភាព មានន័យថា ភាពអាចរកបានទូលំទូលាយ និងលទ្ធភាពទទួលបានព័ត៌មានលំហូរជំនួយក្នុងលក្ខណៈទាន់ពេលវេលា ប្រព័ន្ធ និងអាចប្រៀបធៀបបាន ដែលអនុញ្ញាតឱ្យមានការចូលរួមពីសាធារណៈជន។ | ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០២៣<br><br>World Bank (2017), Procurement in IPF and Other Operational Procurement Matters.<br><br>Australian Government. (2024), Commonwealth Procurement Rules.<br><br>UNDP (2012), Transparency and public procurement. |
| ការប្រកួតប្រជែង | សំដៅដល់ការប្រើប្រាស់នីតិវិធីលទ្ធកម្មដែលមានការចូលរួមពីអ្នកដេញថ្លៃ ដើម្បីជ្រើសរើសសំណុំឯកសារស្នើដេញថ្លៃដែលឆ្លើយតបពេញលេញ ឬសមស្របជាងគេ និងមានតម្លៃល្អបំផុត។ | ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០២៣ |

| | | |
|---|---|---|
| | ប្រកួតប្រជែងបើកចំហ គឺជាវិធីសាស្ត្រលទ្ធកម្មដែលពេញចិត្តរបស់ធនាគារ នៅពេលណាដែលអាចធ្វើទៅបាន ដើម្បីបង្កើនភាពយុត្តិធម៌នៃឱកាសក្នុងការដេញថ្លៃ។ នៅពេលណាដែលអាចធ្វើទៅបាន ធនាគារតម្រូវឱ្យបុគ្គល និងក្រុមហ៊ុនដែលមានសិទ្ធិទទួលបានឱកាសដូចគ្នា ដើម្បីប្រកួតប្រជែងសម្រាប់សកម្មភាពហិរញ្ញវត្ថុរបស់ធនាគារ។ | World Bank, Bank Policy (2017), Procurement in IPF and Other Operational Procurement Matters. |

## ២.៣.ក្របខ័ណ្ឌទ្រឹស្តីនៃលទ្ធកម្មសាធារណៈ

លទ្ធកម្មសាធារណៈ ត្រូវបានគាំទ្រដោយគោលការណ៍មួយចំនួនដែលធានាថាប្រព័ន្ធដំណើរការប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌។ ទ្រឹស្តីមានចំនួនពីរ រួមមានទ្រឹស្តីភ្នាក់ងារចម្បង (Principal-agent theory) និងទ្រឹស្តីជម្រើសសាធារណៈ (Public Choice Theory) ផ្តល់នូវការយល់ដឹងអំពីការគ្រប់គ្រងនៃប្រព័ន្ធលទ្ធកម្មសាធារណៈ។ ទ្រឹស្តីភ្នាក់ងារចម្បង បានបង្ហាញថាភ្នាក់ងារមន្ត្រីលទ្ធកម្មត្រូវបានប្រគល់នូវទំនិញ ឬសេវាកម្មដល់រដ្ឋាភិបាល ដើម្បីធ្វើបម្រើផលប្រយោជន៍សាធារណៈ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែភាពមិនស៊ីសង្វាក់គ្នានៃព័ត៌មាន និងការលើកទឹកចិត្ត មន្ត្រីលទ្ធកម្មអាចធ្វើសកម្មភាពដែលបម្រើផលប្រយោជន៍ផ្ទាល់ខ្លួនការអនុវត្តកិច្ចការលទ្ធកម្មមិនមានប្រសិទ្ធភាព និងកើតមានអំពើពុករលួយ (Jensen & Meckling, 1976)។ ទ្រឹស្តីជម្រើសសាធារណៈបង្ហាញឱ្យឃើញថា ការសម្រេចចិត្តលើលទ្ធកម្មជារឿយៗត្រូវបានជះឥទ្ធិពលដោយផលប្រយោជន៍នយោបាយ និងសេដ្ឋកិច្ច ដែលជាការអនុវត្តមិនស្របនឹងលទ្ធផលគោលនយោបាយរបស់ខ្លួន (Buchanan & Tullock, 1962)។ មូលដ្ឋានគ្រឹះទ្រឹស្តីទាំងនេះបានបង្ហាញពីការផ្តោតសំខាន់លើតម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែងនៅក្នុងប្រព័ន្ធលទ្ធកម្ម ដើម្បីកាត់បន្ថយហានិភ័យនៃអំពើពុករលួយ និងគ្មានប្រសិទ្ធភាព។

## ២.៤ ក្របខ័ណ្ឌលទ្ធកម្មសាធារណៈនៅកម្ពុជា

លទ្ធកម្មសាធារណៈនៅកម្ពុជា គ្រប់គ្រងដោយអនុក្រឹត្យលេខ ១០៥ អនក្រ. ដែលបានចែងគោលការណ៍នីតិវិធីការអនុវត្តលទ្ធកម្មសាធារណៈត្រូវឆ្លងកាត់គោលការណ៍ពីរដ្ឋមន្ត្រី។ ក្របខ័ណ្ឌច្បាប់ក៏កំណត់ថា លទ្ធកម្មសាធារណៈគួរតែត្រូវបានធ្វើឡើងដោយផ្អែកលើគោលការណ៍តម្លាភាព ការប្រកួតប្រជែង ប្រសិទ្ធភាព និងគណនេយ្យភាព (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ ២០០៦)។ ជាច្រើនឆ្នាំកន្លងនេះ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ត្រូវ

បានណែនាំដើម្បីកែលម្អនីតិវិធីលទ្ធកម្ម រួមទាំងការអភិវឌ្ឍន៍វេទិកាលទ្ធកម្មអេឡិចត្រូនិក ការតាមដានត្រួតពិនិត្យបន្ថែមសវនកម្មឯករាជ្យ និងការកសាងសមត្ថភាពសម្រាប់មន្ត្រីលទ្ធកម្ម។ (ធនាគារពិភពលោកឆ្នាំ ២០១៥)

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើរតួនាទីសំខាន់ក្នុងការតាមដានត្រួតពិនិត្យប្រព័ន្ធលទ្ធកម្ម។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានផ្តល់ជាក្របខ័ណ្ឌបទប្បញ្ញត្តិលទ្ធកម្ម និងគោលការណ៍ណែនាំ សារាចរណ៍ណែនាំ និងការតាមដានត្រួតពិនិត្យការអនុលោមដោយអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទោះបីជាមានក្របខ័ណ្ឌនេះក៏ដោយ ការសិក្សាជាច្រើនបានកំណត់បញ្ហាប្រឈមក្នុងការអនុវត្ត រួមទាំងការតាមដានត្រួតពិនិត្យមានកម្រិត អំពើពុករលួយតាមនីតិវិធី និងភាពគ្មានប្រសិទ្ធភាពក្នុងដំណើរការលទ្ធកម្ម។ (តម្លាភាពអន្តរជាតិឆ្នាំ ២០២០)

ការកែទម្រង់លទ្ធកម្មសាធារណៈនៅកម្ពុជា មានទិសដៅឆ្ពោះទៅការអនុវត្តលទ្ធកម្មសាធារណៈតាមបែបវិមជ្ឈការ ដោយផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវទៅឱ្យស្ថាប័នអនុវត្តលទ្ធកម្ម នៅពេលមានក្របខណ្ឌគណនេយ្យច្បាស់លាស់។ កិច្ចលទ្ធកម្មតាមបែបវិសហមជ្ឈការលទ្ធកម្មសាធារណៈ ដោយផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវជាបណ្តើរៗទៅឱ្យស្ថាប័នអនុវត្តលទ្ធកម្ម តាមរយៈការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចលើកិច្ចលទ្ធម្ម ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ ២០០៥ រហូតមកដល់ពេលបច្ចុប្បន្ននេះ។

## ២.៥.ឧត្តមានុវត្តន៍អន្តរជាតិក្នុងការអនុវត្តលទ្ធកម្មសាធារណៈ

ឧត្តមានុវត្តអន្តរជាតិនៃលទ្ធកម្មសាធារណៈ ត្រូវបានដឹកនាំយ៉ាងទូលំទូលាយដោយគោលការណ៍នៃតម្លាភាព យុត្តិធម៌ ប្រសិទ្ធភាព និងគណនេយ្យភាព។ អង្គការអន្តរជាតិជាច្រើនដូចជាធនាគារពិភពលោក OECD និង UNCITRAL បានបង្កើតគោលការណ៍ណែនាំ និងក្របខ័ណ្ឌដែលសង្កត់ធ្ងន់លើការដេញថ្លៃប្រកួតប្រជែង ការបើកចំហលទ្ធភាពទទួលបានព័ត៌មានលទ្ធកម្ម និងឱកាសស្មើគ្នាសម្រាប់អ្នកផ្គត់ផ្គង់ (OECD, 2019)។

ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងប្រទេសមួយចំនួនបានបង្ហាញពីប្រសិទ្ធភាពក្នុងការបង្កើនតម្លាភាព និងកាត់បន្ថយអំពើពុករលួយក្នុងដំណើរការលទ្ធកម្ម។ វេទិកាលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិច ជួយសម្រួលដល់ការដាក់សំណើដេញថ្លៃតាមអេឡិចត្រូនិក ដោយធានាថាដំណើរការនេះមានតម្លាភាព និងបើកចំហចំពោះការតាមដានត្រួតពិនិត្យ ។(ធនាគារពិភពលោកឆ្នាំ ២០១៧)

ជាងនេះទៅទៀត សវនកម្មលទ្ធកម្មឯករាជ្យត្រូវបានប្រើប្រាស់ដោយប្រទេសមួយចំនួនដើម្បីតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃលទ្ធកម្មសាធារណៈ ដូចជាប្រទេសប្រេស៊ីល

និងកូរ៉េខាងត្បូង បានអនុវត្តសវនកម្មលទ្ធកម្មដោយជោគជ័យជាផ្នែកនៃវិធានការប្រឆាំងអំពើពុករលួយទូលំទូលាយ (OECD, 2019)។

នៅក្នុងការប្រៀបធៀប ប្រទេសកម្ពុជាបានចាប់ផ្តើមទទួលយកឧត្តមានុវត្តអន្តរជាតិនៃលទ្ធកម្មសាធារណៈ ជាពិសេសតាមរយៈការសាកល្បងប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិក និងសវនកម្មលទ្ធកម្មសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជានៅតែប្រឈមមុខនឹងការលំបាកក្នុងការអនុវត្តស្របតាមផែនការរបស់ខ្លួនជាមួយនឹងស្តង់ដាអន្តរជាតិ ដោយសារភាពទន់ខ្សោយរបស់ស្ថាប័ន និងឧបសគ្គសមត្ថភាព។
(ធនាគារអភិវឌ្ឍអាស៊ី ឆ្នាំ២០១៨)

## ២.៦.បញ្ហាប្រឈមនៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈរបស់កម្ពុជា

ការសន្សំសំចៃ ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព ការប្រកួតប្រជែងក្នុងលទ្ធកម្មគឺមានសារៈសំខាន់សម្រាប់រដ្ឋាភិបាលក្នុងការធានាថាទទួលបានតម្លៃដ៏ល្អបំផុត និងប្រើប្រាស់ធនធានចំគោលដៅនិងទាន់ពេលវេលា។ ដើម្បីលើកកម្ពស់ដល់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការអនុវត្តលទ្ធកម្មប្រកបដោយសុចរិតភាពគួរតែគាំទ្រដល់គោលដៅរបស់វិស័យសាធារណៈ, ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយការខ្ជះខ្ជាយ និងការចំណាយដែលមិនចាំបាច់, ការប្រើប្រាស់បច្ចេកវិជ្ជា និងឧបករណ៍លទ្ធកម្មអេឡិចត្រូនិក ដើម្បីកាត់បន្ថយបន្ទុករដ្ឋបាល និងការចំណាយឱ្យទាន់ពេលវេលា, ការត្រួតពិនិត្យការអនុវត្តការងារជាប្រចាំ។

ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់កម្ពុជា ត្រូវបានជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនដែលរារាំងដល់ដំណើរការអនុវត្តប្រកបដោយភាពសន្សំសំចៃ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ បញ្ហាប្រឈមទាំងនេះ រួមមាន ការយល់ដឹង និងសមត្ថភាពរបស់មន្ត្រី ការសន្សំសំចៃ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាពនៃការបើកចំហទូលំទូលាយនូវព័ត៌មានអំពីលទ្ធកម្ម គណនេយ្យភាព ការចូលរួមដេញថ្លៃប្រកួតប្រជែងពីប្រជាពលរដ្ឋ ឬអ្នកដេញថ្លៃនៅមានកម្រិត ដែលជាកត្តាកំណត់ទំនុកចិត្ត និងប្រសិទ្ធិភាពនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

## ២.៧. ការសិក្សាសម្មតិកម្ម

នៅក្នុងការសិក្សាស្រាវជ្រាវមួយត្រូវបានបែងចែកឱ្យដាច់រវាងអថេរពីរគឺ អថេរឯករាជ្យ និងអថេរពឹងផ្អែក។ ដោយអថេរទាំង ២ នេះបានដើរតួរយ៉ាងសំខាន់នៅក្នុងការសិក្សាស្រាវជ្រាវ និងអាចនាំឱ្យការសិក្សាស្រាវជ្រាវ មានភាពច្បាស់លាស់ជាងមុន និងងាយស្រួលក្នុងការប្រមូលឯកសារ

និងទន្នន័យជាពិសេសការរៀបចំកម្រងសំណួរនៃប្រធានបទនីមួយៗ។ នៅក្នុងប្រធានបទនេះ ត្រូវបានតាងអថេរឯករាជ្យ និងអថេរពឹងផ្អែកនឹងបានទាញចេញនូវសម្មតិកម្មសំខាន់ៗរួមមាន៖

នៅក្នុងការតាងរបស់អថេរឯករាជ្យ និងអថេរពឹងផ្អែកបានធ្វើឱ្យយើងអាចទាញបាននូវសម្មតិកម្មសំខាន់ៗ ចំនួន ០៤ រួមមាន៖

**សម្មតិកម្ម១៖** ការយល់ដឹង និងសមត្ថភាពមន្ត្រី ទៅលើទំនុកចិត្ត និងប្រសិទ្ធិភាព។

**សម្មតិកម្ម២៖** ការសន្សំសំចៃ ទៅលើទំនុកចិត្ត និងប្រសិទ្ធិភាព។

**សម្មតិកម្ម៣៖** តម្លាភាព និងគណនេយ្យភាព ទៅលើទំនុកចិត្ត និងប្រសិទ្ធិភាព។

**សម្មតិកម្ម៤៖** ការប្រកួតប្រជែង ទៅលើទំនុកចិត្ត និងប្រសិទ្ធិភាព។

### ២.៧.១. ការយល់ដឹង និងសមត្ថភាពមន្ត្រី នៅលើទំនុកចិត្ត និងប្រសិទ្ធិភាព

ការយល់ដឹង និងការចូលរួមរបស់ប្រជាពលរដ្ឋ ក៏ដូចមន្ត្រីនៅថ្នាក់មូលដ្ឋាន គឺជាកាតព្វកិច្ច ជាករណីកិច្ច ជាទុនសង្គមដ៏សំខាន់មិនអាចខ្វះបាន និងជាកត្តា កំណត់ក្នុងការពង្រឹងអភិបាលកិច្ចល្អដែលគាំទ្រដល់ដំណើរការនៃការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅកម្ពុជាដើម្បីឈានទៅសម្រេចការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិឱ្យកាន់តែរីកចម្រើន លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាប្រកបដោយសមធម៌ និងមាននិរន្តរភាព។ (https://ncdd.gov.kh)

នៅក្នុងការអនុវត្តជាក់ស្តែងមានភាពប្រែប្រួលទៅតាមមាត្រដ្ឋាន តំបន់ ប្រភព និងជម្រៅ Goulet (1989) បានរៀបរាប់ថា ចាប់ពីការចូលរួមខ្នាតតូចក្នុងគ្រួសារ រហូតដល់សកម្មភាពចូលរួមយ៉ាងច្រើននៅថ្នាក់ជាតិ។ វិសាលភាពនៃបញ្ហាដែលគ្របដណ្តប់នៅក្នុងជួរនេះអាចមានលក្ខណៈទូលំទូលាយ។ ការចូលរួមអាចត្រូវបានជំរុញពីខាងលើ ដោយអ្នកជំនាញ ឬអាជ្ញាធរ ឬប្រជាពលរដ្ឋ ឬអាចត្រូវបានជំរុញដោយភ្នាក់ងារទីបី។ ជម្រៅនៃការចូលរួមអាចនឹងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងពេលវេលាដែលមនុស្សត្រូវបាននែនាំទៅក្នុងដំណើរការនេះ។

ទន្ទឹមនឹងនេះផងដែរ Oakley (1991) បានបញ្ជាក់ថាការបែងចែករវាងការចូលរួមជាមធ្យោបាយ និងការចូលរួមជាការបញ្ចប់។ ជាមធ្យោបាយមួយ ការចូលរួមត្រូវបានប្រើប្រាស់ដើម្បីសម្រេចបាននូវគោលដៅ ឬគោលបំណងនៃគម្រោងកាន់តែប្រសើរឡើង ដូចជាការផ្តល់សេវា (មុខងារ) ការចូលរួម ហើយត្រូវបានគេមើលឃើញថាជាដំណើរការដែលមនុស្សអភិវឌ្ឍ និងពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការអន្តរាគមន៍ដោយផ្ទាល់ ឬគ្រប់គ្រងគំនិតផ្តួចផ្តើមនៃការអភិវឌ្ឍ។ ការយល់ដឹងនៃធាតុចូលរួមផ្សេងគ្នាទាំងនេះ គឺជាភាពខុសគ្នាខាងទស្សនវិជ្ជាទាក់ទងនឹងអ្នកដែលមានសមត្ថភាព និងសិទ្ធិគ្រប់គ្រងដំណើរនៃការអភិវឌ្ឍ។

ការកសាងសមត្ថភាពជូនដល់មន្ត្រីលទ្ធកម្ម ជាការដែលត្រូវផ្ដោតការយកចិត្តទុកដាក់ខ្ពស់ស្របពេលដែលការផ្ដល់សិទ្ធិអំណាច និងការទទួលខុសត្រូវជាបណ្ដើរៗទៅឱ្យស្ថាប័នអនុវត្តលទ្ធកម្មតាមរយៈការបង្កើនទឹកប្រាក់សិទ្ធិសម្រេចលើកិច្ចលទ្ធកម្មត្រូវបានធ្វើឡើងជាបន្តបន្ទាប់ និងទំហំទឹកប្រាក់កាន់ច្រើនឡើង។ ការចូលរួមរបស់មន្ត្រីដែលទទួលបន្ទុកអនុវត្តលទ្ធកម្មសាធារណៈដោយផ្ទាល់ ក្នុងការចូលរួមវគ្គបណ្ដុះបណ្ដាលដើម្បីបង្កើនសមត្ថភាពមន្ត្រី ពិតមានផលប៉ះពាល់យ៉ាងសំខាន់ទៅអភិបាលកិច្ចល្អក្នុងនាមជាអន្តរកម្មនៃការគ្រប់គ្រង អភិបាលស្វែងរកការចែករំលែកអំពីអំណាចនៅក្នុងដំណើរកាលនៃសេចក្ដីសម្រេចចិត្ត និងផ្ដល់ឱ្យប្រជាពលរដ្ឋលើទំនុកចិត្ត និងប្រសិទ្ធិភាពនៃការអនុវត្ត។

### ២.៧.២. ការសន្សំសំចៃ ទៅលើទំនុកចិត្ត និងប្រសិទ្ធិភាព

យោងតាម Lukas Vogel (2009) បានបញ្ជាក់ថា រាជរដ្ឋាភិបាលអាចកាត់បន្ថយពន្ធ បង្កើនបរិមាណនៃតម្រូវការសាធារណៈ បង្កើនការផ្ទេរប្រាក់ទៅគ្រួសារ ឬបង់ប្រាក់ឧបត្ថម្ភបន្ថែមដល់វិស័យឯកជន។ គោលនយោបាយផ្សេងៗមានភាពខុសប្លែកគ្នានៅក្នុងតម្រូវការ និងផលប៉ះពាល់នៃការផ្គត់ផ្គង់៖ កម្លាំងពលកម្មទាប និងការយកពន្ធមូលធនមាននិន្នាការបង្កើនការផ្គត់ផ្គង់កម្លាំងពលកម្ម និងការវិនិយោគ។ ការប្រើប្រាស់រដ្ឋាភិបាលខ្ពស់បង្កើនតម្រូវការសរុប ខណៈពេលដែលការវិនិយោគរបស់រដ្ឋាភិបាលបន្ថែមការកែលម្អរយៈពេលវែងនៃផលិតភាពកត្តាទៅនឹងផលប៉ះពាល់តម្រូវការ។ ការផ្ទេរប្រាក់កាន់តែខ្ពស់អាចបង្កើនប្រាក់ឈ្នួលកក់របស់កម្មករ ដោយមានផលប៉ះពាល់អវិជ្ជមានលើការផ្គត់ផ្គង់កម្លាំងពលកម្ម។ ការឧបត្ថម្ភធនដល់អ្នកផលិតបានផ្លាស់ប្តូរថ្លៃដើម និងតម្លៃដែលទាក់ទងគ្នា ដើម្បីគាំទ្រដល់វិស័យឧបត្ថម្ភធននៃសេដ្ឋកិច្ច។

ការបង្កើនការប្រកួតប្រជែងរវាងអ្នកផ្គត់ផ្គង់លទ្ធកម្មអាចកាត់បន្ថយនៃការបង្កើនតម្លៃបន្ថែមលើថ្លៃទំនិញ និងសេវារបស់អ្នកផ្គត់ផ្គង់ផងដែរ។ វាក៏អាចបង្កើនការដេញថ្លៃលើទំនិញ និងសេវាកម្មទទួលបានគុណភាព និងបរិមាណល្អផងដែរ។

ការសន្សំសំចៃនៃដំណើរការលទ្ធកម្មសាធារណៈ ពិតជាមានផលប៉ះពាល់ទៅលើទំនុកចិត្ត និងប្រសិទ្ធិភាព នៃដំណើរការដែលរដ្ឋាភិបាល ស្ថាប័នសាធារណៈ និងស្ថាប័នផ្សេងទៀតទទួលបានទំនិញ និងសេវាកម្មពីអ្នកផ្គត់ផ្គង់ ឬអ្នកម៉ៅការខាងក្រៅ។ ដំណើរការនេះជាប់ពាក់ព័ន្ធនឹងសំណុំនីតិវិធី ច្បាប់ និងបទប្បញ្ញត្តិដែលបានរៀបចំឡើង ដើម្បីធានាថាថវិកាជាតិត្រូវបានចំណាយប្រកបដោយប្រសិទ្ធភាព តម្លាភាព និងអនុលោមតាមច្បាប់ និងគោលនយោបាយ។ លទ្ធកម្មសាធារណៈដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ច ដោយសារតែជាចំណែកមួយដ៏សំខាន់នៃការចំណាយសាធារណៈ ហើយក៏អាចបង្កជាផលប៉ះពាល់ដល់ការអភិវឌ្ឍន៍ប្រទេសជាតិផងដែរដូចជាការចំណាយខ្ជះខ្ជាយប្រសិនបើអនុវត្តមិនត្រឹមត្រូវ។

### ២.៧.៣.តម្លាភាព និងគណនេយ្យភាព ទៅលើទំនុកចិត្ត និងប្រសិទ្ធិភាព

យោងតាមអង្គការសហប្រជាជាតិ (២០១១) បានបញ្ជាក់ថានៅក្នុងលទ្ធកម្មសាធារណៈ គោលដៅនៃភាពយុត្តិធម៌ ការប្រកួតប្រជែង និងតម្លៃសេដ្ឋកិច្ចគឺសំខាន់បំផុត។ ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធភាព ដំណើរការលទ្ធកម្មដ៏ត្រឹមត្រូវមួយត្រូវតែបង្កើតឡើង។ នេះរួមបញ្ចូលទាំងការបញ្ចូលការគ្រប់គ្រងគ្រប់គ្រាន់ទៅលើកកម្ពស់ការប្រកួតប្រជែង និងកាត់បន្ថយហានិភ័យនៃការក្លែងបន្លំ អំពើពុករលួយ ការខ្ជះខ្ជាយ និងការគ្រប់គ្រងសាធារណៈមិនត្រឹមត្រូវមូលនិធិ។ ក្នុងបរិបទនេះផងដែរ តម្លាភាពត្រូវបានពិចារណាជាឧបករណ៍ដ៏មានប្រសិទ្ធភាពបំផុតមួយក្នុងការទប់ស្កាត់អំពើពុករលួយនិងធានាបាននូវតម្លៃសម្រាប់ប្រាក់។

តម្លាភាពត្រូវបានចាត់ទុកថាជាតម្រូវការជាមុនដើម្បីធានាការទទួលខុសត្រូវរបស់មន្ត្រីសាធារណៈ។ ក្នុងន័យនេះ មានការព្រមព្រៀងយ៉ាងទូលំទូលាយប្រសិទ្ធភាពនៃតម្លាភាពអាចមានបន្ថែមទៀតពង្រឹងដោយការពង្រឹងការត្រួតពិនិត្យ និងអង្គការឃ្លាំមើលសង្គមស៊ីវិលពិនិត្យលើលទ្ធកម្ម ព្រោះពួកគេអាចដើរតួយ៉ាងសំខាន់តួនាទីជាអ្នកឃ្លាំមើលសម្រាប់សុចរិតភាពក្នុងវិស័យសាធារណៈ។

ការពិនិត្យមើលសមត្ថភាពនៃតម្លាភាព ដើម្បីធ្វើឱ្យមានតុល្យភាពឡើងវិញនូវភាពមិនស្មើគ្នានៃព័ត៌មានដែលមាននៅក្នុងដំណើរការលទ្ធកម្ម។ ការគ្របដណ្តប់លទ្ធភាព និងដែនកំណត់ទាំងនេះ វិធានការជាឧបករណ៍សម្រាប់លើកកម្ពស់សុចរិតភាព និងទប់ស្កាត់អំពើពុករលួយក្នុងលទ្ធកម្ម។ នេះត្រូវបានបន្តដោយអំណះអំណាងមួយអំពីរបៀបតម្លាភាព
វិធានការត្រូវបានបំពេញយ៉ាងល្អបំផុតដោយវិធានការការលើកកម្ពស់ការប្រកួតប្រជែង។ Anderson, Kovacic & Muller (2011) អះអាងថា តម្លាភាពអាចធានាបាននូវសុចរិតភាពក្នុងចំណោមមន្ត្រីសាធារណៈ ការលើកកម្ពស់ការប្រកួតប្រជែងវិធានការចាំបាច់ ដើម្បីទប់ស្កាត់ការឃុបឃិតគ្នារវាងសហគមន៍អ្នកផ្គត់ផ្គង់។

នៅក្នុងវិស័យលទ្ធកម្មកំពុងបន្តជំរុញការអនុវត្ត កំណត់ និងដោះស្រាយបញ្ហាស្មុគស្មាញទាក់ទងនឹងការអនុវត្តវិធានការតម្លាភាព។ នេះនឹងអនុញ្ញាតឱ្យមានតម្លាភាពដែលបង្កើនគណនេយ្យភាព ខណៈពេលដែលមិនរារាំងប្រសិទ្ធភាព និងប្រសិទ្ធភាពនៃដំណើរការលទ្ធកម្ម។ ហើយនិន្នាការនេះជំរុញដល់អាជ្ញាធរលទ្ធកម្មសាធារណៈដើម្បីបង្កើនតម្លាភាពក្នុងដំណើរការកិច្ចលទ្ធកម្ម។ ទោះជាយ៉ាងណាក៏ដោយក៏នៅមានឧបសគ្គសំខាន់ៗដែលត្រូវជម្នះ ប្រសិនបើគោលការណ៍តម្លាភាពត្រូវប្រើឱ្យពេញលេញ ដើម្បីក្លាយជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការលើក

កម្ពស់ការប្រកួតប្រជែង កម្ចាត់អំពើពុករលួយ ធ្វើឱ្យមន្ត្រីសាធារណៈមានការទទួលខុសត្រូវខ្ពស់ និងពង្រឹងអភិបាលកិច្ចជារួមក្នុងលទ្ធកម្មសាធារណៈ។ Isabelle Adam (2024).

### ២.៧.៤. ការប្រកួតប្រជែង នៅលើទំនុកចិត្ត និងប្រសិទ្ធិភាព

ការប្រកួតប្រជែងគឺជាធាតុសំខាន់នៃក្របខ័ណ្ឌលទ្ធកម្មរបស់រដ្ឋាភិបាលអូស្រ្តាលី។ ការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យមានការមិនរើសអើង និងការប្រើប្រាស់ដំណើរការលទ្ធកម្មប្រកួតប្រជែង។ ការមិនរើសអើង៖ អ្នកផ្គត់ផ្គង់សក្តានុពលទាំងអស់ដល់រដ្ឋាភិបាលត្រូវតែជាកម្មវត្ថុនៃវិធានលទ្ធកម្មលើទ្រព្យសកម្ម(Commonwealth Procurement Rules) ទាំងនេះត្រូវបានប្រព្រឹត្តដោយសមធម៌ដោយផ្អែកលើសមត្ថភាពពាណិជ្ជកម្ម ច្បាប់ បច្ចេកទេស និងហិរញ្ញវត្ថុរបស់ពួកគេ ហើយមិនត្រូវបានរើសអើងដោយសារទំហំ កម្រិតនៃភាពពាក់ព័ន្ធជាមួយបរទេស ឬកម្មសិទ្ធិ ទីតាំង ឬ ប្រភពដើមនៃទំនិញ និងសេវាកម្មរបស់ពួកគេ។ សហគ្រាសធុនតូច និងមធ្យម៖ ដើម្បីធានាថាសហគ្រាសធុនតូច និងមធ្យម (SMEs) អាចចូលរួមក្នុងការប្រកួតប្រជែងដោយស្មើភាពសម្រាប់ធុរកិច្ចរដ្ឋាភិបាលអូស្រ្តាលី មន្ត្រីគួរតែអនុវត្តការអនុវត្តលទ្ធកម្មដែលមិនមានការរើសអើងដោយអយុត្តិធម៌ចំពោះសហគ្រាសធុនតូច និងមធ្យម និងផ្តល់ឱកាសសមរម្យសម្រាប់សហគ្រាសធុនតូច និងមធ្យមក្នុងការប្រកួតប្រជែង។ (រាជរដ្ឋាភិបាលអូស្រ្តាលី, ឆ្នាំ២០២៤) http://www.finance.gov.au

យោងតាមធនាគារអភិវឌ្ឍអាស៊ីបានលើកទឹកចិត្តឱ្យមានការប្រកួតប្រជែងបើកចំហជាវិធីសាស្រ្តលទ្ធកម្មដែលពេញចិត្ត នៅពេលណាដែលអាចធ្វើទៅបាន ដើម្បីបង្កើនភាពយុត្តិធម៌នៃឱកាសក្នុងការដេញថ្លៃ។ ការប្រកួតប្រជែងបើកចំហគឺជាមូលដ្ឋានសម្រាប់លទ្ធកម្មសាធារណៈប្រកបដោយប្រសិទ្ធភាព។ អ្នកខ្ចីត្រូវជ្រើសរើសវិធីសាស្រ្តសមស្របបំផុតសម្រាប់លទ្ធកម្មជាក់លាក់។ ក្នុងករណីភាគច្រើន ការដេញថ្លៃប្រកួតប្រជែងអន្តរជាតិ (ICB) ដែលគ្រប់គ្រងបានត្រឹមត្រូវ និងជាមួយនឹងការអនុញ្ញាតសម្រាប់ចំណូលចិត្តសម្រាប់ទំនិញដែលផលិតក្នុងស្រុក ហើយបើសមស្រប សម្រាប់អ្នកម៉ៅការក្នុងស្រុក 5 សម្រាប់ការងារក្រោមលក្ខខណ្ឌកំណត់គឺជាវិធីសាស្រ្តសមស្របបំផុត។ ដូច្នេះក្នុងករណីភាគច្រើន ADB តម្រូវឱ្យអ្នកខ្ចីរបស់ខ្លួនទទួលបានទំនិញ ការងារ និងសេវាកម្មតាមរយៈ (ICB) បើកចំហសម្រាប់អ្នកផ្គត់ផ្គង់ និងអ្នកម៉ៅការដែលមានសិទ្ធិ។

កង្វះការប្រកួតប្រជែងមិនត្រូវកំណត់ដោយផ្អែកទៅលើចំនួនអ្នកដេញថ្លៃនោះទេ។ សូម្បីតែនៅពេលដែលការដេញថ្លៃតែមួយត្រូវបានដាក់ស្នើក៏ដោយ ដំណើរការដេញថ្លៃអាចចាត់ទុកថាមានសុពលភាព ប្រសិនបើការដេញថ្លៃត្រូវបានផ្សព្វផ្សាយដោយពេញចិត្ត ហើយតម្លៃគឺសមហេតុផលក្នុងការប្រៀបធៀបទៅនឹងតម្លៃទីផ្សារ។ (ធនាគារអភិវឌ្ឍអាស៊ី ឆ្នាំ ២០១៥)

ការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនៃលទ្ធកម្មសាធារណៈ ទាមទារឱ្យមានកម្រិតខ្ពស់ទាំងតម្លាភាព និងការប្រកួតប្រជែង។ វិធានការនានាក្នុងគោលបំណងលើកកម្ពស់តម្លាភាពគឺស្របទៅនឹងការលើកកម្ពស់ការប្រកួតប្រជែង ប៉ុន្តែមានតម្រូវការសម្រាប់ស្របាស្រ័យគ្នាទៅវិញទៅមកនៃកង្វល់ទាំងពីរ។ វិធានការតម្លាភាពមានសារៈសំខាន់ក្នុងការធានាសុច្ចរិតភាពរបស់មន្ត្រីសាធារណៈ ប៉ុន្តែវិធានការទាំងនេះមិនអាចធានាបាននូវដំណើរការដ៏ល្អប្រសើរនៃទីផ្សារលទ្ធកម្មសាធារណៈតែម្នាក់ឯងបានទេ ដោយសារពួកគេមិនដោះស្រាយការអនុវត្តរួមនៅខាងអ្នកផ្គត់ផ្គង់។ វិធានការលើកកម្ពស់ការប្រកួតប្រជែងក៏សំខាន់ផងដែរ។ (ធនាគារពិភពលោក ឆ្នាំ២០១៧)

## ២.៨. កំណែទម្រង់ និងគំនិតផ្តួចផ្តើមថ្មីៗ

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលគោលបំណងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធលទ្ធកម្មសាធារណៈដែលបានដាក់ចេញនូវសកម្មភាពដូចខាងក្រោម៖

កម្មវិធីពង្រឹងសមត្ថភាព៖ កម្មវិធីបណ្តុះបណ្តាលផ្សេងៗត្រូវបានបង្កើតឡើង ដើម្បីបង្កើនជំនាញរបស់មន្ត្រីលទ្ធកម្ម។ កម្មវិធីទាំងអស់នេះផ្តោតសំខាន់ទៅលើឧត្តមានុវត្តនៃលទ្ធកម្មសាធារណៈ ដើម្បអនុវត្តប្រកបដោយតម្លាភាព និងគណនេយ្យភាព។ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,២០១៦)

លទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖ កម្ពុជាបានចាប់ផ្តើមសាកល្បងប្រព័ន្ធលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីជួយសម្រួលដល់ការដាក់សំណើដេញថ្លៃតាមអេឡិចត្រូនិក និងបង្កើនតម្លាភាពក្នុងដំណើរការដេញថ្លៃ។ ទោះបីជានៅតែស្ថិតក្នុងដំណាក់កាលដំបូងនៃការបង្កើតគំនិតផ្តួចផ្តើម ត្រូវបានគេមើលឃើញថាជាជំហានវិជ្ជមានឆ្ពោះទៅរកការកាត់បន្ថយអំពើពុករលួយ និងមិនមានប្រសិទ្ធភាពក្នុងលទ្ធកម្មសាធារណៈ។ (ធនាគារអភិវឌ្ឍអាស៊ី ឆ្នាំ២០១៨)

## ២.៩.ទិដ្ឋភាពសំខាន់ៗនៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃក្នុងលទ្ធកម្មសាធារណៈនៅកម្ពុជា

ក្របខ័ណ្ឌច្បាប់៖ លទ្ធកម្មសាធារណៈរបស់ប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (២០២៣) និងបទប្បញ្ញត្តិពាក់ព័ន្ធ។ ច្បាប់ទាំងនេះកំណត់នីតិវិធីសម្រាប់ការដេញថ្លៃប្រកួតប្រជែង ការគ្រប់គ្រងកិច្ចសន្យា និងការទទួលខុសត្រូវរបស់អង្គភាពលទ្ធកម្ម។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ តាមដានត្រួតពិនិត្យគោលនយោបាយលទ្ធកម្ម និងធានាការអនុលោមតាមបទប្បញ្ញត្តិ។

យន្តការត្រួតពិនិត្យ៖ រដ្ឋាភិបាលកម្ពុជាបានបង្កើតយន្តការជាច្រើន ដើម្បីតាមដានត្រួតពិនិត្យសកម្មភាពលទ្ធកម្ម។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយលទ្ធកម្ម ការប្រគល់កិច្ចសន្យាលទ្ធកម្ម និងធានាការប្រកាន់ខ្ជាប់នូវស្តង់ដារជាតិ។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ តាមដានពិនិត្យដំណើរការដេញថ្លៃ ប្រគល់កិច្ចសន្យា និងការគ្រប់គ្រងកិច្ចសន្យា ដើម្បីរកមើលភាពមិនប្រក្រតី និងអំពើពុករលួយដែលអាចកើតមាន។

ដំណើរការវាយតម្លៃ៖ ការវាយតម្លៃលើលទ្ធកម្មសាធារណៈផ្តោតលើ លទ្ធផលនៃកិច្ចលទ្ធកម្មត្រូវគ្នាទៅនឹងគោលដៅដែលបានគ្រោងទុកដូចជា ប្រសិទ្ធភាពចំណាយ ភាពទាន់ពេលវេលា និងគុណភាពនៃសេវាកម្ម ឬទំនិញដែលបានទទួល។

កិច្ចខិតខំប្រឹងប្រែងកំណែទម្រង់៖ ប្រទេសកម្ពុជាបានចាត់វិធានការកែលម្អប្រព័ន្ធលទ្ធកម្មសាធារណៈជាបន្តបន្ទាប់ ដែលជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ កំណែទម្រង់រួមមានការដាក់បញ្ចូលប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិក និងការអនុវត្តស្រមតាមឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីបង្កើនតម្លាភាព និងប្រសិទ្ធភាព។ (យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៨ ២០២៥)

## ២.១០.សិក្សាពីប្រព័ន្ធលទ្ធកម្មសាធារណៈពីបណ្តាប្រទេសនៅអាស៊ាន

កម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលកម្ពុជាអាចសិក្សារៀនសូត្រប្រព័ន្ធលទ្ធកម្មសាធារណៈរបស់ ប្រទេសដូចជាម៉ាឡេស៊ី និងវៀតណាមបានកែលម្អប្រព័ន្ធលទ្ធកម្មដោយជោគជ័យ ដោយការពង្រឹងក្របខ័ណ្ឌច្បាប់ បង្កើនតម្លាភាពតាមរយៈ លទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការបង្កើតស្ថាប័នតាមដានត្រួតពិនិត្យឯករាជ្យ (OECD, 2019)។ ប្រទេសទាំងនេះបានបង្ហាញថាឆន្ទៈនយោបាយចូលរួមចំណែកក្នុងការអនុវត្តកំណែទម្រង់ស្ថាប័នឱ្យមានភាពល្អប្រសើរជានាបាននូវប្រសិទ្ធភាព និងសុចរិតភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈ។

## ២.១១. ការរំលឹកវិធីសាស្ត្រស្រាវជ្រាវ

យោងតាមការរំលឹកទ្រឹស្តី ការយល់ដឹង និងសមត្ថភាពមន្ត្រីទទួលបន្ទុកអនុវត្តការងារលទ្ធកម្ម , ការសន្សំសំចៃ, តម្លាភាព និងគណនេយ្យភាព, និងការប្រកួតប្រជែង គឺជាអថេរមិនឯករាជ្យ (IV) និងទំនុកចិត្ត និងប្រសិទ្ធិភាព គឺជាអថេរឯករាជ្យ (DV)។

## តារាងទំនាក់ទំនងរវាងអថេរមិនឯករាជ្យ និងអថេរឯករាជ្យ



# ជំពូកទី ៣

# សិក្សាពីការអនុវត្តលទ្ធកម្មសាធារណៈ

## ៣.១.សេចក្តីផ្តើម

គោលបំណងនៃក្នុងជំពូកនេះ គឺជាការសិក្សាលើក្របខ័ណ្ឌច្បាប់បទប្បញ្ញត្តិ វិធីសាស្ត្រ និងនីតិវិធីនៃការអនុវត្តលទ្ធកម្មសាធារណៈ។ នៅក្នុង ជំពូកនេះ ត្រូវបានបែងចែកជា ៣ផ្នែក។ ផ្នែកទី១ ក្របខ័ណ្ឌគតិយុត្ត។ ផ្នែកទី២ ទិដ្ឋភាពទូទៅ។ ផ្នែកទី៣ ការអនុវត្តលទ្ធកម្មសាធារណៈរបស់រដ្ឋបាលខេត្តប៉ៃលិន សម្រាប់ឆ្នាំ២០២១។

## ៣.២.ក្របខ័ណ្ឌគតិយុត្ត

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា ដែលក្នុងមានការគ្រប់គ្រងកិច្ចលទ្ធកម្មគឺជាផ្នែកមួយនៃសកម្មភាពស្នូលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការតាមដានត្រួតពិនិត្យ និងគ្រប់គ្រងកិច្ចលទ្ធកម្មសាធារណៈរបស់ប្រទេសកម្ពុជា។

យោងតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបញ្ជាក់ថាដើម្បីកំណត់អំពីវិធាន វិធីសាស្ត្រ និងនីតិវិធីក្នុងការអនុវត្តលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំច្បាប់បទប្បញ្ញត្តិជាច្រើនរួមមាន៖ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ, អនុក្រឹត្យស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម, អនុក្រឹត្យស្តីពីបែបបទនិងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងលទ្ធកម្ម, ប្រកាសស្តីពីការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម, ប្រកាសស្តីពីការពិនិត្យ និងអនុម័តផែនការលទ្ធកម្មរបស់មន្ទីរជំនាញរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ, ប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្ម, ប្រកាសស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា, និងបទប្បញ្ញត្តិផ្សេងៗ ដែលបានផ្សព្វផ្សាយដោយអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

## ៣.៣.ទិដ្ឋភាពទូទៅ

លទ្ធកម្មសាធារណៈបានក្លាយជាបញ្ហានៃការយកចិត្តទុកដាក់ និងការជជែកដេញដោលរបស់សាធារណៈជន ហើយត្រូវបានទទួលរងនូវការកែទម្រង់ ការរៀបចំរចនាសម្ព័ន្ធឡើងវិញ ច្បាប់ និងបទប្បញ្ញត្តិ។ លទ្ធកម្មសាធារណៈសំដៅទៅលើសកម្មភាពរបស់រដ្ឋាភិបាលក្នុងការទិញទំនិញ និងសេវាកម្មដែលត្រូវការដើម្បីបំពេញមុខងាររបស់ខ្លួន (Arrowsmith, 2010)។ Odhiambo and

Kamau (2003) បានកំណត់លទ្ធកម្មសាធារណៈថាជាការទិញទំនិញ និងកិច្ចសន្យាការងារ និងសេវាកម្មសំណង់ ប្រសិនបើការទិញយកបែបនេះគឺ ឥទ្ធិពលនៃធនធានពីថវិការដ្ឋ ថវិកាអាជ្ញាធរមូលដ្ឋាន មូលនិធិមូលនិធិរដ្ឋ ប្រាក់កម្ចីក្នុងស្រុក ឬកម្ចីបរទេសដែលធានាដោយរដ្ឋ បរទេស ជំនួយក៏ដូចជាប្រាក់ចំណូលដែលទទួលបានពីសកម្មភាពសេដ្ឋកិច្ចរបស់រដ្ឋ។ លទ្ធកម្មសាធារណៈ មានន័យថា លទ្ធកម្មដោយអង្គភាពលទ្ធកម្ម ដោយប្រើមូលនិធិសាធារណៈ (ធនាគារពិភពលោក ១៩៩៥, Kipchilat, 2006)។

លទ្ធកម្មគឺជាធាតុសំខាន់មួយនៅក្នុងមុខងារការងាររបស់រដ្ឋណាមួយ ដោយសារវាត្រូវបានប្រើសម្រាប់ការទិញទំនិញ និងសេវាកម្មក្នុងគុណភាពត្រឹមត្រូវ ពីប្រភពត្រឹមត្រូវ និងក្នុងតម្លៃសមរម្យទាំងអស់ ដើម្បីបំពេញតម្រូវការជាក់លាក់មួយ។ រដ្ឋាភិបាលនីមួយៗមានកាតព្វកិច្ចក្នុងការផ្តល់សេវាសំខាន់ៗដល់ប្រជាពលរដ្ឋរបស់ខ្លួនតាមរយៈលទ្ធកម្មសាធារណៈ។ លទ្ធកម្មសាធារណៈមានប្រភពដើមនៅក្នុងកាតព្វកិច្ច នៃរដ្ឋបាលរបស់រដ្ឋាភិបាលក្នុងការចែកចាយទំនិញ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដល់ប្រជាជននៃប្រទេសមួយ ឬតំបន់ភូមិសាស្រ្តជាក់លាក់មួយ ទីក្រុង ឬទីក្រុង (Odhiambo and Kamau, 2003)។ វាគឺជាមុខងារសំខាន់របស់រាជរដ្ឋាភិបាលសម្រាប់ ហេតុផលជាច្រើន។ ទំហំនៃលទ្ធកម្មដ៏ច្រើនសន្ធឹកសន្ធាប់មានឥទ្ធិពលយ៉ាងខ្លាំងទៅលើសេដ្ឋកិច្ច ហើយចាំបាច់ត្រូវគ្រប់គ្រងឱ្យបានល្អ។ ជាការពិតណាស់ នៅក្នុងប្រទេសទាំងអស់ក្នុងពិភពលោក ការប៉ាន់ប្រមាណនៃសកម្មភាពហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រងលទ្ធកម្មរបស់រដ្ឋាភិបាលត្រូវបានគេជឿថាស្ថិតនៅក្នុងលំដាប់ 10% - 30% នៃ GNP (Callender & Mathews, 2000)។

នៅក្នុងពិភពលោកទាំងមូល គ្រប់ស្ថាប័នអាជីវកម្មទាំងអស់ពឹងផ្អែកលើការបំប្លែងធាតុចូល (ទំនិញ/សេវាកម្ម) ទៅជាលទ្ធផលទាំងរូបី និងអរូបី ដែលត្រូវតែដាក់ឱ្យដំណើរការនៅក្នុងប្រព័ន្ធដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាព ដើម្បីធានាឱ្យប្រតិបត្តិការរបស់ខ្លួនដំណើរការប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ យោងតាមរបាយការណ៍លទ្ធកម្មរបស់ប្រទេសថៃ (2001) គោលការណ៍ជាមូលដ្ឋាននៃការអនុវត្តលទ្ធកម្មល្អ រួមមានគណនេយ្យភាព ដែលយន្តការប្រកបដោយប្រសិទ្ធភាពត្រូវតែមាន ដើម្បីឱ្យអង្គភាពលទ្ធកម្មចំណាយធនធានដែលមានកម្រិតដោយប្រុងប្រយ័ត្ន ដោយដឹងយ៉ាងច្បាស់ថាមានទំនួលខុសត្រូវចំពោះសមាជិកសាធារណៈ។ ការផ្តត់ផ្គង់ប្រកួតប្រជែង ដែលតម្រូវឱ្យលទ្ធកម្មត្រូវបានអនុវត្តដោយការប្រកួតប្រជែង លុះត្រាតែមានហេតុផលគួរឱ្យជឿជាក់សម្រាប់ប្រភពតែមួយ។ និងភាពស៊ីសង្វាក់គ្នា ដែលសង្កត់ធ្ងន់លើការប្រព្រឹត្តិដោយស្មើភាពគ្នារបស់អ្នកដេញថ្លៃទាំងអស់ ដោយមិនគិតពីពូជសាសន៍ សញ្ជាតិ ឬទំនាក់ទំនងនយោបាយ។

នៅក្នុងប្រទេសកំពុងអភិវឌ្ឍ លទ្ធកម្មសាធារណៈត្រូវបានទទួលស្គាល់កាន់តែខ្លាំងឡើងថាជាកត្តាសំខាន់ក្នុងការផ្តល់សេវា (Basheka & Bisangabasaija, 2010) ហើយវាមានសមាមាត្រខ្ពស់នៃការចំណាយសរុប។ ឧទាហរណ៍ លទ្ធកម្មសាធារណៈមានចំនួន 58% នៅក្នុងប្រទេសអង់ហ្គោឡា 40% នៅម៉ាឡាវី និង 70% នៃការចំណាយសាធារណៈរបស់អ៊ូហ្គង់ដា (Wittig, 1999; Government of Uganda, 2006) ដូចដែលបានលើកឡើងនៅក្នុង Basheka and Bisangabasaija (2010)។

ច្បាប់លទ្ធកម្មសាធារណៈ និង ច្បាប់ត្រូវបានចាត់ទុកថាជាសសរស្តម្ភដ៏សំខាន់បំផុតនៃប្រព័ន្ធលទ្ធកម្មប្រទេសថៃ (ថៃ, ២០០៩)។ ច្បាប់ និងវិធានលទ្ធកម្មនាំទៅរកប្រសិទ្ធភាពលទ្ធកម្ម ឬគ្មានប្រសិទ្ធភាព អាស្រ័យលើរាជរដ្ឋាភិបាល និងបរិស្ថានជុំវិញដែលប្រព័ន្ធនេះត្រូវបានដាក់ដំណើរការ។ នៅក្នុងប្រទេសដែលមិនមានលទ្ធិប្រជាធិបតេយ្យរបស់រដ្ឋាភិបាល ប្រព័ន្ធលទ្ធកម្មមិនអាចមានតម្លាភាព និងរួមបញ្ចូលបានទេ (អង្គការសម្រាប់សាជីវកម្មសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ (OECD, 2006))។

យោងទៅតាម American Bar Association (2000) ប្រព័ន្ធលទ្ធកម្មសាធារណៈល្អត្រូវតែមានច្បាប់លទ្ធកម្មល្អ និងបទប្បញ្ញត្តិយោងទៅតាមធនាគារពិភពលោក (2006) ប្រព័ន្ធលទ្ធកម្មសាធារណៈត្រូវបានគេនិយាយថាមានដំណើរការល្អប្រសិនបើវាសម្រេចបាននូវគោលបំណងនៃតម្លាភាព ការប្រកួតប្រជែង សេដ្ឋកិច្ច និងគណនេយ្យភាព។

ប្រព័ន្ធលទ្ធកម្មសាធារណៈប្រកបដោយប្រសិទ្ធភាពអាចរួមចំណែកយ៉ាងធំធេងដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេសកេនយ៉ា ហើយជាពិសេសគឺជាមូលដ្ឋានគ្រឹះនៃការសម្រេចបាននូវចក្ខុវិស័យឆ្នាំ 2030។ រាជរដ្ឋាភិបាលនៃប្រទេសកេនយ៉ាគឺជាអ្នកផ្តល់សេវាសំខាន់ៗដូចជាសុខភាព ការអប់រំ ការការពារជាតិ និងហេដ្ឋារចនាសម្ព័ន្ធ។ នេះត្រូវបានធ្វើតាមរយៈមុខងារលទ្ធកម្ម ដែលធ្វើឱ្យវាមានសារៈសំខាន់ខ្លាំងណាស់ ហើយទំហំនៃលទ្ធកម្មដ៏ច្រើនសន្ធឹកសន្ធាប់មានឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ច ហើយចាំបាច់ត្រូវគ្រប់គ្រងឱ្យបានល្អ។ ប្រទេសនីមួយៗមានបរិយាកាសសេដ្ឋកិច្ច សង្គម វប្បធម៌ និងនយោបាយរៀងៗខ្លួន ដូច្នេះហើយអ្នកអនុវត្តលទ្ធកម្មសាធារណៈរបស់ប្រទេសនីមួយៗប្រឈមមុខនឹងបញ្ហាប្រឈមផ្សេងៗគ្នា ជាក់ស្តែងនៅក្នុងប្រទេសទាំងអស់ក្នុងពិភពលោក ការប៉ាន់ប្រមាណនៃសកម្មភាពហិរញ្ញវត្ថុនៃលទ្ធកម្មរបស់រដ្ឋាភិបាលត្រូវបានគេជឿថាមាននៅក្នុង 10%-30% នៃ GNP (Callender & Mathews, 2005)។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ និងជាអ្នកកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្រ្តនៃលទ្ធកម្ម រៀបចំគោលនយោបាយ និងនីតិវិធីលម្អិតនៃ

លទ្ធកម្មសម្រាប់ការអនុវត្តឱ្យស្របទៅតាមបទប្បញ្ញត្តិដែលមានស្រាប់អោយកាន់តែមានភាពល្អប្រសើរ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានភារកិច្ចត្រួតពិនិត្យកែលម្អ និងបំពេញបន្ថែមទៅលើវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។ រាល់ការកែលម្អ ឬការបំពេញបន្ថែមត្រូវធ្វើឡើងដោយប្រកាស ឬសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បំពេញមុខងារជាសេនាធិការលើការងារគ្រប់គ្រងលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សាដែលអនុវត្តដោយក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត។ (ប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ រួមមាន៖ នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ, នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ, នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់ និងសេវា, នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ និងនាយកដ្ឋានត្រួតពិនិត្យ និងដោះស្រាយវិវាទ។ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

ស្ថាប័នអនុវត្តលទ្ធកម្មចាំបាច់ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ របស់ខ្លួនតាមតារាងគំរូដែលផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប្រធានស្ថាប័នអនុវត្តលទ្ធកម្មត្រូវពិនិត្យ លើផែនការលទ្ធកម្ម រួចផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័តតាមរយៈអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈឱ្យបានយ៉ាងយូរបំផុតត្រឹម សប្តាហ៍ទី១ ខែមករា នៃឆ្នាំសារពើពន្ធ។ រាល់គម្រោងចំណាយត្រូវអនុវត្ត តាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មត្រូវកត់ត្រាទាំងអស់តាមលំដាប់លំដោយហើយបញ្ចូលក្នុងផែនការលទ្ធកម្ម។ (ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

ដើម្បីគ្រប់គ្រងដំណើរការលទ្ធកម្មប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព អង្គភាពលទ្ធកម្មតាមរយៈក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ គឺតម្រូវឱ្យបញ្ចូលផែនការលទ្ធកម្មរបស់អគ្គនាយកដ្ឋានលទ្ធកម្មជាមុនសិន ដើម្បីផ្តល់ផែនការលទ្ធកម្មសាជីវកម្មរបស់អង្គភាព ដែលមុននឹងអនុវត្តត្រូវទទួលបានការយល់ព្រមពីមន្ត្រីគណនេយ្យ។ នេះបញ្ជាក់ថា ផែនការលទ្ធកម្មទាំងអស់ត្រូវតែរួមបញ្ចូលយ៉ាងល្អទៅក្នុងដំណើរការថវិកា ដោយផ្អែកលើថវិកាចង្អុលបង្ហាញថាសមស្រប និងអនុលោមតាមច្បាប់លទ្ធកម្ម។

ប្រធានស្ថាប័នអនុវត្តលទ្ធកម្មមានភារកិច្ចគ្រប់គ្រង និងត្រួតពិនិត្យជាប្រចាំនូវកិច្ចលទ្ធកម្មរបស់ស្ថាប័នខ្លួន ហើយត្រូវធានាឱ្យបានថារាល់កិច្ចលទ្ធកម្ម រួមទាំងការងារវិសហមជ្ឈការលទ្ធកម្មសុទ្ធតែត្រូវបានអនុវត្តត្រឹមត្រូវស្របតាមវិធីសាស្ត្រ នីតិវិធី និងផែនការលទ្ធកម្ម។ ស្ថាប័នអនុវត្ត

លទ្ធកម្មត្រូវធ្វើរបាយការណ៍ប្រចាំខែ ស្តីពីការអនុវត្តគកិច្ចលទ្ធកម្ម ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ និងការប្រគល់កិច្ចសន្យា ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈឱ្យបានទៀងទាត់រៀងរាល់ខែ។ (អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣)

## ៣.៤.ការអនុវត្តលទ្ធកម្មសាធារណៈរបស់រដ្ឋបាលខេត្តប៉ៃលិន សម្រាប់ឆ្នាំ ២០២១

ខេត្តប៉ៃលិន មានទីតាំងស្ថិតនៅប៉ែកខាងលិច នៃព្រះរាជាណាចក្រកម្ពុជា មានប្រវែងចំងាយ ប្រមាណ ៣៧១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ដែលមានព្រំប្រទល់៖ ខាងជើងជាប់នឹងស្រុកកំរៀង ខេត្តបាត់ដំបង, ខាងត្បូងជាប់នឹង ស្រុកសំឡូត ខេត្តបាត់ដំបង, ខាងកើតជាប់នឹង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និង ខាងលិចជាប់នឹង ស្រុកពោងណាំរ៉ង ខេត្តច័ន្ទបូរី ប្រទេសថៃឡង់ដ៏។ (រដ្ឋបាលខេត្តប៉ៃលិន, ២០១៩)

យោងតាមរដ្ឋបាលខេត្តប៉ៃលិនបានបញ្ជាក់ថា ទំហំផ្ទៃដីសរុបរបស់ខេត្តប៉ៃលិនមាន ១ ០៦២ គីឡូម៉ែត្រការ៉េ ដែលក្នុងនោះមាន ដីសម្រាប់ដំណាំកសិកម្ម ៧៥ ៩៤៦ ហិចតាដីតំបន់ភ្នំ និងអភិរក្ស ចំនួន ១៤ ៤៥៤ ហិចតា និងដីសំរាប់លំនៅដ្ឋានមាន ១៥ ៨០០ ហិចតា។ ខេត្តប៉ៃលិន ចែកចេញជាក្រុងប៉ៃលិន និងស្រុកសាលាក្រៅ មាន ០៤ សង្កាត់ និង ០៤ ឃុំ ភូមិចំនួន ៩០ ភូមិ មានប្រជាពលរដ្ឋសរុប ១៥ ២៣១ គ្រួសារ មនុស្សសរុបចំនួន ៧០ ៦១៥ នាក់ ស្រី ៣៤ ៨៦៧ នាក់ ដង់ស៊ីតេ គិតជាមធ្យម គឺ ៦៦ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េប្រជាជនភាគច្រើនប្រកបរបរធ្វើចំការ ស្រែ កម្មករ លក់ដូរ រកត្បូង និង សិប្បកម្មកែច្នៃជាដើម ។ រចនាសម្ព័ន្ធរដ្ឋបាលខេត្តប៉ៃលិនមានក្រុមប្រឹក្សាខេត្ត មានអង្គភាព និងយន្តការក្រោមឱវាទដូចជា៖ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស, គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ, គណៈកម្មាធិការលទ្ធកម្ម, គណៈកម្មាធិការនានា និងគណៈអភិបាលខេត្តប៉ៃលិន។

ទន្ទឹងនឹងនេះផងដែរ គណៈអភិបាលខេត្តប៉ៃលិន ក៏មានសេនាធិការដែលជួយដល់ការដឹកនាំ រៀបចំ ផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍហេដ្ឋានរចនាសម្ព័ន្ធផ្លូវថ្នល់សាលារៀន មានដូចជា នាយក-នាយករងរដ្ឋបាលខេត្ត, ទីចាត់ការរដ្ឋបាល (ការិយាល័យរបៀបនិងឯកសារ, ការិយាល័យទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ, ការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន, ការិយាល័យលេខាក្រុមប្រឹក្សា, ការិយាល័យសរុប និងព័ត៌មាន), ទីចាត់ការផែនការនិងវិនិយោគ (ការិយាល័យវិនិយោគ, ការិយាល័យផែនការ, ការិយាល័យគាំទ្រមូលដ្ឋាន), ទីចាត់ការហិរញ្ញវត្ថុ (ការិយាល័យហិរញ្ញកិច្ច, ការិយាល័យគណនេយ្យ, ការិយាល័យទ្រព្យសម្បត្តិ), ទីចាត់ការគ្រប់គ្រងធនធានមនុស្ស (ការិយាល័យគ្រប់គ្រងបុគ្គលិក និងការិយាល័យក

សាងសមត្ថភាព),ទីចាត់ការអន្តរវិស័យ (ការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់, ការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច, ការិយាល័យកិច្ចច្បាប់ និងសុវត្ថិភាពសាធារណៈ), អង្គភាពលទ្ធកម្ម និងអង្គភាពច្រកចេញចូលតែមួយ។ (រដ្ឋបាលខេត្តប៉ៃលិន, ២០១៩)

យោងតាមរបាយការណ៍លទ្ធកម្មឆ្នាំ២០២១ បានបង្ហាញឱ្យឃើញថា រដ្ឋបាលខេត្តប៉ៃលិន បានលើកគ្រោងផែនការលទ្ធកម្មដោយបែងចែកតែទៅលើលទ្ធកម្មទំនិញដែលមានចំនួនសរុប ៥៦០លានរៀល រួមមាន៖ ប្រេងឥន្ទនៈ និងប្រេងរំអិល (ឆមាសទី១)មានចំនួន ៥០លានរៀល, សម្ភារៈការិយាល័យ (ឆមាសទី១) មានចំនួន ៥០លានរៀល, ឯកសណ្ឋាន មានចំនួន ៤០លានរៀល, សម្ភារៈបរិក្ខាបច្ចេកទេសមិនមែនព័ត៌មានវិទ្យា មានចំនួន ៥០លានរៀល, សង្ហារឹម មានចំនួន ៥០លានរៀល, សម្ភារៈបរិក្ខាបច្ចេកទេសព័ត៌មានវិទ្យា មានចំនួន ១០០លានរៀល, សោហ៊ុយទទួលភ្ញៀវជាតិ មានចំនួន ២០លានរៀល, ឧបត្ថម្ភប្រជាជនសម្រាកពេទ្យ-ចំណាយដំណើរការរបស់មណ្ឌលសុខភាព មានចំនួន ១០០លានរៀល, ប្រេងឥន្ទនៈ និងប្រេងរំអិល (ឆមាសទី២) មានចំនួន ៥០លានរៀល និង សម្ភារៈការិយាល័យ (ឆមាសទី២) មានចំនួន ៥០ លានរៀល។

(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, ឆ្នាំ២០២១)

# ជំពូកទី ៤

# វិធីសាស្ត្រស្រាវជ្រាវ

## ៤.១.សេចក្ដីផ្ដើម

គោលបំណងនៃជំពូកនេះគឺដើម្បីពន្យល់ពីវិធីសាស្ត្រដែលត្រូវបានប្រើក្នុងការសិក្សាបច្ចុប្បន្ន។ សម្រាប់ គោលបំណងនៃជំពូកនេះត្រូវបានចែកជា ៦ ផ្នែក។ ផ្នែកទី១ ប្រភេទនៃការវិភាគទិន្នន័យ ការកំណត់ទំហំសំណាក និងបច្ចេកទេសជ្រើសរើសសំណាក ផ្នែកទី២ ប្រភេទ និងប្រភពទិន្នន័យ ផ្នែកទី៣ ឧបករណ៍ក្នុងការវិភាគទិន្នន័យ ផ្នែកទី៤ នីតិវិធីនៃការប្រមូលទិន្នន័យ នៅផ្នែកទី៥ បរិយាយ និងគណនាពីភាពទុកចិត្តនៃកម្រងសំណួរ និងផ្នែក៦ ចុងក្រោយជាសេចក្ដីសន្និដ្ឋាន។

## ៤.២. ប្រភេទនៃការវិភាគទិន្នន័យ

ប្រភេទនៃការវិភាគទិន្នន័យដែលបានធ្វើឡើងនីក្នុងការសិក្សាគឺជាបរិមាណនៅក្នុងធម្មជាតិ ហើយការវិភាគលើការកត្តាកំណត់ការយល់ដឹង និងសមត្ថភាពរបស់ប្រជាពលរដ្ឋ និងមន្ត្រីអនុវត្តលទ្ធកម្ម, ការសន្សំសំចៃក្នុងកិច្ចលទ្ធកម្ម, តម្លាភាព និងគណនេយ្យភាព និងការប្រកួតប្រជែង នៃការអនុវត្តលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន ទៅលើផលប៉ះពាល់នៃទំនុកចិត្ត និងប្រសិទ្ធិភាព ត្រូវបានអនុវត្តតាមលក្ខណៈបរិមាណវិស័យ។ ជាមួយគ្នានេះដែរ ក្នុងការសិក្សាស្រាវជ្រាវទាំងអស់ត្រូវប្រើប្រាស់ទិន្នន័យបឋម ជាការស្ទង់មតិប្រជាពលរដ្ឋ និងមន្ត្រីរាជការជាក់ស្តែងនៅក្នុងខេត្តប៉ៃលិន និងត្រូវបានប្រើប្រាស់ការវិភាគទិន្នន័យបែបគុណភាព និងបរិមាណ ឬយើងស្គាល់ថា ជាការវិភាគទិន្នន័យបែប Qualitative research និង Quantitative research ។ ដោយផ្អែកលើទ្រឹស្តី និងប្រភេទនៃការវិភាគទិន្នន័យស្របតាមការសិក្សាផ្សេងៗទៀតដែលបានធ្វើការសិក្សាស្រាវជ្រាវលើទំនាក់ទំនងនៃការយល់ដឹង និងសមត្ថភាពរបស់ប្រជាពលរដ្ឋ និងមន្ត្រីអនុវត្តលទ្ធកម្ម, ការសន្សំសំចៃក្នុងកិច្ចលទ្ធកម្ម, តម្លាភាព និងគណនេយ្យភាព និងការប្រកួតប្រជែងប្រកបដោយភាពយុត្តិធម៌ ភាគច្រើនគេប្រើប្រាស់ការវិភាគតាមបែបបរិមាណវិស័យ ឬ Quantitative research ដែលការវិភាគនេះនឹងផ្អែកលើលទ្ធផលដែលទទួលបានមកពីការសម្ភាសន៍ដោយប្រើជាកម្រងសំណួរប្រភេទខ្លីៗ បែបយល់ស្រប ឬមិនយល់ស្រប នេះបើយោងតាមការសិក្សាស្រាវជ្រាវមួយដែលបង្ហាញពីការរៀបចំបទសម្ភាសន៍ជាក្រុម ឬជាបុគ្គល ដើម្បីទទួលបានមតិយោបល់ទៅលើអាក្បកិរិយា បទពិសោធន៍ ការវាយតម្លៃទៅលើអត្តចរិត ការយល់ដឹង និងសមត្ថភាពនៃការតបនៃសំណួរ របស់អ្នកសម្ភាសន៍ដើម្បីទទួលបានលទ្ធផលពិតប្រាកដជាក់ស្តែង (Rowley, 2012)។

## ៤.៣ ទំហំសំណាក និងការជ្រើសរើសសំណាក

ការប្រមូលសំណាក និងប៉ាន់គំរូគឺយើងជ្រើសរើសតែប្រជាពលរដ្ឋ និងមន្ត្រីមូលដ្ឋានមួយចំនួនដែលបានកំណត់ថាពួកគាត់កំពុងរស់នៅ និងបំពេញការងារ ក្នុងខេត្តប៉ៃលិនតែប៉ុណ្ណោះ។ ហើយការវិភាគនេះគឺត្រូវបានផ្តោតសំខាន់ទៅលើកត្តាកំណត់នៃការយល់ដឹង និងសមត្ថភាពមន្ត្រីអនុវត្ត, ការសំនៀសំចៃ, តម្លាភាព និងគណនេយ្យភាព និងការប្រកួតប្រជែង ដែលមានផលប៉ះពាល់នៃទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តកិច្ចលទ្ធកម្មក្នុងខេត្តប៉ៃលិនផ្ទាល់។ ក្នុងការគណនានេះ ការសិក្សាត្រូវស្គាល់ថាកម្រិតជឿជាក់ក្នុងការគណនាដើម្បីទទួលបានសំណាកពិតប្រាកដ។ ក្នុងករណីការសិក្សានេះ ត្រូវបានបញ្ជាក់ជាភាគរយ និងតំណាងឱ្យចំនួនភាគរយពិតនៃចំនួនសាកលភាព (Population) ដែលនឹងជ្រើសរើសចម្លើយស្ថិតនៅក្នុងគម្លាតនៃភាពជឿជាក់។ នៅពេលដែលកម្រិតជឿជាក់ ៩៥% មានន័យថាលទ្ធផលនៃការគណនារកទំហំសំណាកអាចលម្អៀងនូវកម្រិត ៥%។ បើសិនជាកម្រិតជឿជាក់ ៩៩% មានន័យថាលទ្ធផលនៃការគណនាទំហំសំណាកអាចលម្អៀងនូវកម្រិត ១%។ សម្រាប់ករណីសិក្សានេះ ការគណនាទំហំសំណាកត្រូវបានប្រើប្រាស់ក្នុងកម្រិតលម្អៀងកម្រិត ៥ភាគរយ ដោយផ្អែកតាមរយៈរូបមន្តរបស់យ៉ាសម៉ាន Yamane (1967) សម្រាប់គណនារកទំហំសំណាកដោយផ្អែកលើចំនួនប្រជាពលរដ្ឋ និងមន្ត្រីថ្នាក់មូលដ្ឋានស្ថិតខេត្តប៉ៃលិនចំនួន ១,០០០នាក់។ តាមរូបមន្ត $n = \frac{N}{1+\mathrm{N(e)}^2}$ ដែល $n$ ជាទំហំសំណាក, $N$ ជាចំនួនប្រជាពលរដ្ឋ, $e$ ជាកម្រិតលម្អៀង ៥%។ ដោយការជ្រើសរើសចំនួនប្រជាពលរដ្ឋ និងមន្ត្រីថ្នាក់មូលដ្ឋានក្នុងខេត្តប៉ៃលិនមានចំនួន ១,០០០នាក់ ដូច្នេះទំហំសំណាកគឺ

$n = \frac{1000}{1+1000(0.05)^2} = 286$ នាក់។ នៅក្នុងលក្ខខណ្ឌនៃច្បាប់ទំហំសំណាក នៅក្នុងបរិបទធម្មជាតិនៃការសិក្សាបែបចិត្តសាស្ត្រ ដែលទាក់ទងនឹងការអង្កេតដែលពាក់ព័ន្ធនឹងបញ្ហាដូចជា ការធ្វើតេស្តសមត្ថភាព វង្វាស់អាកប្បកិរិយា ឬបុគ្គលិកលក្ខណៈជាដើម យោងតាម (Rules of Thumb for Minimum Sample Size for Multiple Regression, n.d.) បានបញ្ជាក់ថាការសិក្សាអាចកំណត់បានថា៖ បើទំហំសំណាក (n)=១០០ មានន័យថា "គ្រប់គ្រាន់"។ ប្រសិនទំហំសំណាក (n)= ២០០ ទទួលបានកម្រិត "ល្អ" និងក្នុងករណីបើគណនាឃើញថាទំហំសំណាក (n) មានចំនួនចាប់ពី ៤០០ ឡើងទៅគឺ "អស្ចារ្យ"។ ដូច្នេះសម្រាប់ទំហំសំណាកនៃការសិក្សាបច្ចុប្បន្នមានចំនួន ២៨៦ នាក់ ជាចំនួនដែលអាចទទួលយកបានក្នុងកម្រិត "ល្អបង្គួរ" ហើយសម្រាប់ការសិក្សាប្រមូលទិន្នន័យ។

## ៤.៤.ប្រភពទិន្នន័យ

នៅក្នុងការស្រាវជ្រាវនេះ ត្រូវបានប្រើប្រាស់ទាំងវិធីសាស្ត្រតាមបែបគុណវិស័យ ដែលទិន្នន័យទាំងអស់ត្រូវបានប្រមូលតាមរយៈការសង្កេត ការសាកសួរជាសំណួរទៅកាន់មន្ត្រីថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន និងនិស្សិតដែលកំពុងសិក្សាផ្នែករដ្ឋបាលសាធារណៈ ព្រមទាំងបានយកទិន្នន័យតាមអត្ថបទច្បាប់ ឯកសាររដ្ឋបាលសាធារណៈ របាយការណ៍ លិខិតបទដ្ឋានគតិយុត្តនានា និងឯកសារស្រាវជ្រាវផ្សេងៗ តាមរយៈអ៊ិនធើណែត បណ្ណាល័យ បណ្ណាគារផងដែរ។

ការប្រមូលទិន្នន័យ គឺមានសារៈសំខាន់ណាស់ម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងប្រមូលឯកសារមកចងក្រង ដើម្បីរៀបរៀងឡើងក្នុងការបំពេញឱ្យគ្រប់លក្ខខណ្ឌ និងយកមកធ្វើជារបាយការណ៍ទ្រឹស្តីដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ប្រកបដោយ ភាពជោគជ័យ និងប្រសិទ្ធភាពខ្ពស់។ ដើម្បីប្រមូលបានទិន្នន័យល្អៗ និងគ្រប់គ្រាន់ទៅតាមគោលបំណងចង់បាននោះ ក្នុងដំណាក់កាលនេះត្រូវធ្វើការប្រមូលទិន្នន័យតាមប្រភពពីរ គឺទិន្នន័យចម្បង (Primary Data) និងទិន្នន័យបន្ទាប់បន្សំ (Secondary Data)។

ទិន្នន័យចម្បង (Primary Data) គឺជាប្រភេទទិន្នន័យទាំងឡាយណាដែលបានពីការសម្ភាសន៍ផ្ទាល់ ឬមិនផ្ទាល់ជាមួយប្រជាពលរដ្ឋ និងអ្នកដែលពាក់ព័ន្ធទាំងអស់ ដោយប្រើជាកម្រងសំណួរប្រភេទខ្លីៗ (Questionnaires) បែបយល់ស្រប ឬមិនយល់ស្រប ។

ទិន្នន័យបន្ទាប់បន្សំ (Secondary Data) គឺជាប្រភេទទិន្នន័យដែលអាចប្រមូលបានពីសំណុំឯកសារដែលមានស្រាប់ និងងាយស្រួលទទួលបានពីបណ្តាញសង្គម វេបសាយ ។ល។ ទិន្នន័យទាំងនេះបានដកស្រង់មកពីក្រសួងមហាផ្ទៃ វិទ្យាស្ថានជាតិស្ថិតិ អត្ថបទផ្សព្វផ្សាយ និងឯកសារផ្សេងៗតាមរយៈអ៊ិនធើណែត សៀវភៅ និងបណ្ណាល័យ។

## ៤.៥.ឧបករណ៍ក្នុងការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនៃទិន្នន័យដែលទទួលបានត្រូវយកមកបញ្ចូលទៅក្នុងកម្មវិធី SPSS និងវិភាគទិន្នន័យដោយប្រើស្ថិតិពណ៍នា។ លទ្ធផលដែលទទួលបានត្រូវយកវិភាគតាមបែបវិទ្យាសាស្ត្រដោយប្រើប្រាស់នូវឧបករណ៍ស្ថិតិដូចជា៖ ការវិភាគទី១គឺស្វែងរកអត្តសញ្ញាណអ្នកឆ្លើយតបតាមរយៈ Frequency, Percentage, Table និង Graph ។ ការវិភាគទី២ គឺស្វែងរកការវាយតម្លៃទំនុកចិត្ត និងប្រសិទ្ធិភាពដោយការប្រើប្រាស់ឧបករណ៍ Weight Arithmetic Mean។ សម្រាប់វិភាគទី៣ គឺការប្រើប្រាស់ឧបករណ៍ Regression វាយតម្លៃពីផលប៉ះពាល់នៃការយល់ដឹង និងសមត្ថភាពមន្ត្រី, ការសន្សំសំចៃកិច្ចលទ្ធកម្ម, តម្លាភាព និងគណនេយ្យភាព និងការប្រកួតប្រជែងប្រកបយុត្តិធម៌ នៃការអនុវត្តលទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិស្ថិតក្នុងខេត្តប៉ៃលិន។

## ៤.៦.វិធីសាស្ត្រនៃការវិភាគទិន្នន័យ

ក្នុងដើម្បីឆ្លងតបទៅតាមការរកឃើញនៃចំនួនសំណាកដែលបនាជ្រើសរើស យើងបាន ធ្វើការរៀបចំជាកម្រងសំណួរចំនួន ២៨៦ នាក់ ដើម្បីធ្វើការសាកសួរដោយផ្ទាល់ ឬមិនផ្ទាល់ ទៅកាន់ប្រជាពលរដ្ឋ និងមន្ត្រីមូលដ្ឋានក្នុងការឆ្លើយតប និងទុករយៈពេលសមរម្យជូនពួកគាត់ធ្វើការពិចារណា និងសម្រេចចិត្តប្រកបដោយឆន្ទៈ។ ពួកគាត់មានសិទ្ធិស្នើសុំការពន្យល់បន្ថែម ដើម្បីទទួលបាននូវចម្លើយ ឬលទ្ធផលដ៏ត្រឹមត្រូវពិតប្រាកដមួយ។

កម្រងសំណួរ នឹងរួមបញ្ចូលសំណួរស្តីពិទិដ្ឋភាពជាច្រើនទាក់ទងនឹងប្រធានបទនៃការស្រាវជ្រាវដូចជា អត្តសញ្ញាណរបស់អ្នកឆ្លើយសំណួរដែលទាក់ទងទៅនឹងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈនៅខេត្តប៉ៃលិន។ ក្នុងដំណើរការរៀបចំកម្រងសំណួរ សំណួរនីមួយសម្រាប់អថេរខាងលើបានផ្ទៀងផ្ទាត់យ៉ាងច្បាស់ និងប្រាកដក្នុងចិត្តថាអត្តន័យក្នុងសំណួរស្របទៅនឹងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។ លើសពីនេះ មុនពេលកម្រងសំណួរត្រូវបានប្រើសម្រាប់ប្រមូលទិន្នន័យបឋមពីអ្នកឆ្លើយតបនឹងសំណួរទៅតាមទំហំដែលបានកំណត់រួចមកសេចក្តីព្រាងកម្រងសំណួរនេះ ត្រូវបានធ្វើតេស្តសាកល្បងមុននឹងដាក់ឱ្យប្រើប្រាស់ និងបានធ្វើការសាលល្បងវិភាគតាមរយៈកម្មវិធី SPSS ក្នុងកុំព្យូទ័រ ដើម្បីបញ្ជាក់ឱ្យបានច្បាស់ថារង្វាស់ដែលបានប្រើតាមអថេរនីមួយៗ មានភាពបន្សំគ្នាទៅនឹងឧបករណ៍ស្ថិតិដែលបានគ្រោងទុក ឬបើអាចខុសឆ្គងពាក្យពេចន៍ខ្លឹមសារនៃសំណួរណាមួយងាយនឹងមានការកែតម្រូវចាំបាច់ជាមុន ទើបការសម្រេចចិត្តទិន្នន័យតាមទំហំសំណាកពិតប្រាកដត្រូវអនុវត្ត។ ជាចុងក្រោយបន្ទាប់ពីការប្រមូលនូវលទ្ធផលពីចំនួនទាំង ២៨៦ នាក់រួច យើងអាចធ្វើការបញ្ចូលទិន្នន័យទាំងនោះទៅក្នុងកម្មវិធី SPSS Version ។

## ៤.៧.ភាពជឿជាក់នៃទិន្នន័យ

នៅក្នុងចំណុចនេះ ដើម្បីបញ្ជាក់ឱ្យមានការជឿជាក់ ច្បាស់លាស់ពិប្រាកដ ត្រឹមត្រូវ និងសុក្រឹត្យភាព កិច្ចការស្រាវជ្រាវអំពីកត្តាកំណត់ទំនុកចិត្ត និងប្រសិទ្ធិភាពនៃការអនុវត្តលទ្ធកម្មសាធារណនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងខេត្តប៉ៃលិន បានសម្រេចប្រើប្រាស់នូវអាលហ្វា (Cronbach's Alpha) ដើម្បីជារង្វាស់នៃភាពស្ថិតស្ថេរផ្ទៃក្នុងដែលពេលនិយមប្រើប្រាស់នៅក្នុងវិស័យចិត្តស្រាស្ត និងធ្វើតេស្តជាធាតុដែលអាចទុកចិត្តបាននៃកម្រងសំណួរនៅក្នុងឧបករណ៍នឹងត្រូវបានគណនា តាមរូបមន្តៈ

$$\alpha=\frac{k}{k-1}\left(1-\frac{\sum_{i=1}^{k}\sigma_y^2}{\sigma_x^2}\right)$$

Cronbach Alpha គឺជារង្វាស់នៃភាពអាចជឿជាក់បានដែលមានចាប់ពី 0.00 ដល់ ១.0 ជាមួយនឹងតម្លៃខ្ពស់ដែលបង្ហាញពីភាពជឿជាក់កាន់តែច្រើន។

| No | Coefficient of Cronbach Alpha | Reliability Level |
|---|---|---|
| ១ | >0.៩0 | ល្អណាស់ |
| ២ | 0.៨0-0.៨៩ | ល្អ |
| ៣ | 0.៧0-0.៧៩ | ល្អបង្គួរ |
| ៤ | 0.៦0-0.៦៩ | មធ្យម |
| ៥ | 0.៥0-0.៥៩ | ខ្សោយ |
| ៦ | <0.៥0 | មិនអាចទទួលយកបាន |

<u>តារាងទី២៖ អាល់ហ្វា (ភាពជឿជាក់នៃទិន្នន័យ)</u>

| ល.រ | សម្ភតិកម្ម | ចំនួន | អាល់ហ្វា | ការវាយតម្លៃ |
|---|---|---|---|---|
| ១ | ការយល់ដឹង និង សមត្ថភាពមន្ត្រី | ៥ | 0.៨៤៣ | ល្អ |
| ២ | ការសន្សំសំចៃ | ៥ | 0.៨៩១ | ល្អ |
| ៣ | តម្លាភាព និង គណនេយ្យភាព | ៥ | 0.៨៧៥ | ល្អ |
| ៤ | ការប្រកួតប្រជែង | ៥ | 0.៨៨២ | ល្អ |

តាមរយៈលទ្ធផលដែលទទួលបាននៅក្នុងតារាងខាងលើ ភាពជឿជាក់នៃអាល់ហ្វា ចំពោះសម្មតិកម្មទី១ ការយល់ដឹង និងសមត្ថភាពមន្ត្រីគឺ 0.៨៤៣, សម្មតិកម្មទី២ ការសន្សំសំចៃកិច្ចលទ្ធកម្ម គឺ 0.៨៩១, សម្មតិកម្មទី៣ តម្លាភាព និងគណនេយ្យភាព គឺ 0.៨៧៥ និងសម្មតិកម្មទី៤ ការប្រកួតប្រជែង គឺ 0.៨៨២។ ជារួម ចំពោះភាពជឿជាក់នៃសម្មតិកម្មទាំង ៤ គឺល្អ។ ដូច្នេះភាពជឿជាក់នៃការវាយតម្លៃចំពោះសម្មតិកម្មបង្ហាញពីភាពទុកចិត្ត ចំពោះកម្រងសំណួរ។

# ជំពូកទី ៥

# ការវិភាគទិន្នន័យ

## ៥.១.សេចក្តីផ្តើម

គោលបំណងនៃជំពូកនេះ  គឺដើម្បីធ្វើការវិភាគទៅលើទិន្នន័យដែលប្រមូលបាននិងទាញយកលទ្ធផលមកបកស្រាយ ។ ការវិភាគទិន្នន័យរួមមានប្រភេទដូចជា៖ ព័ត៌មានទូទៅរបស់អ្នកផ្តល់សម្ភាសន៍, វាយតម្លៃប្រសិទ្ធិភាព ដោយជំពូកនេះ ត្រូវបានបែងចែកជា ៣ ផ្នែកសំខាន់ៗ រួមមាន ផ្នែកទី១ វិភាគអំពីអត្តសញ្ញាណ អ្នកផ្តល់សម្ភាសន៍, ផ្នែកទី២ វិភាគពីមធ្យមមេគុណដើម្បីកំណត់រកភាពលម្អៀងនៃរង្វាស់វិភាគតាម Regression ដើម្បីកំណត់ទំនាក់ទំនងរបស់ អថេរមិនឯករាជ្យ និង អថេរឯករាជ្យ និងចុងក្រោយជាការបកស្រាយលទ្ធផល។

## ៥.២. ព័ត៌មានទូទៅរបស់អ្នកផ្តល់សម្ភាសន៍

តាមរយៈការសម្រង់មតិយោបល់ដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះ  យើងមានចំនួនអ្នកចូលរួមផ្តល់ចម្លើយពីកម្រងសំណួរនៅរដ្ឋបាលខេត្តប៉ៃលិន សរុបចំនួន ២៨៦នាក់ ប៉ុន្តែលទ្ធផលដែលយើងអាចឆ្លើយតបបាន  និងសន្លឹកកិច្ចការដែលបានការមានចំនួនត្រឹមតែ  ២៥៨នាក់តែប៉ុណ្ណោះ។ យើងទទួលបានការបង្ហាញឱ្យឃើញថាពីកម្រិតនៃភាពជឿជាក់របស់កម្រងសំណួរតាមរយៈការវិភាគកម្មវិធី SPSS រួចមក យើងទទួលបានលទ្ធផលសម្មតិកម្មទាំង៤ គឺភាពជឿជាក់អាល់ហ្វាសម្រាប់សម្មតិកម្មនីមួយៗ ដូចខាងក្រោម៖

### ៥.២.១ ភេទរបស់អ្នកផ្តល់សម្ភាសន៍

យោងតាមទិន្នន័យដែលបានបង្ហាញខាងក្រោមបានបញ្ជាក់ថាក្នុងចំណោមទិន្នន័យ  បានការចំនួន ២៥៨ នាក់ ក្នុងនោះ ភេទបុរសមានចំនួន ៥៨% និងភេទស្រីមានចំនួន ៤២%។

<u>ក្រាហ្វិចទី១៖ ទិន្នន័យភេទរបស់អ្នកផ្តល់សម្ភាសន៍</u>



### ៥.២.២ អាយុរបស់អ្នកផ្តល់សម្ភាសន៍

យោងតាមទិន្នន័យដែលបានបង្ហាញក្នុងក្រាហ្វិចខាងក្រោមនេះ បានបង្ហាញឱ្យឃើញថា ក្នុងចំណោមប្រជាពលរដ្ឋ និងមន្ត្រីមូលដ្ឋាន ចំនួន ២៥៨ នាក់ ក្នុងនោះ អ្នកដែលមានអាយុចន្លោះចាប់ពី ១៨-២៥ ឆ្នាំ មានចំនួន ២០%។ អាយុចន្លោះចាប់ពី ២៥-៣៥ ឆ្នាំ មានចំនួន ២៦%។ អាយុចន្លោះចាប់ពី ៣៥-៤៥ឆ្នាំ មានចំនួន ២៤%។ អាយុលើសពី ៤៥ ឆ្នាំ មានចំនួន ៣០%។

**ក្រាហ្វិចទី២៖ ទិន្នន័យអាយុរបស់អ្នកផ្តល់សម្ភាសន៍**




### ៥.២.៣ កម្រិតសិក្សាអ្នកផ្តល់សម្ភាសន៍

យោងតាមទិន្នន័យទទួលបានពីការផ្តល់សម្ភាសន៍ ក្នុងចំណោម ២៥៨ នាក់ យើងសង្កេតឃើញថាប្រជាពលរដ្ឋ និងមន្ត្រីថ្នាក់មូលដ្ឋានដែលបានបញ្ចប់ការសិក្សាត្រឹមថ្នាក់វិទ្យាល័យមានកម្រិតមធ្យមភាគខ្ពស់ជាងគេ គឺមានចំនួន ៣៣,៥%។ បន្ទាប់មកទៀតគឺប្រជាពលរដ្ឋ និងមន្ត្រីមូលដ្ឋានដែលបានបញ្ចប់ការសិក្សាត្រឹមកម្រិតអនុវិទ្យាល័យមានចំនួន ៣០,៥%។ ចំណែកឯប្រជាពលរដ្ឋ និងមន្ត្រីមូលដ្ឋានដែលបានបញ្ចប់ការសិក្សាត្រឹមកម្រិតថ្នាក់បរិញ្ញាបត្រគឺមានចំនួន ២៦,៧% និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៨%។ ដោយឡែកប្រជាពលរដ្ឋ និងមន្ត្រីមូលដ្ឋានដែលបានបញ្ចប់ការសិក្សាដល់កម្រិតបណ្ឌិតមានចំនួន ១,៣% តែប៉ុណ្ណោះ។

## ដ្យាក្រាមទី៣៖ កម្រិតសិក្សាអ្នកផ្ដល់សម្ភាសន៍




### ៥.២.៣ តួនាទីរបស់អ្នកផ្ដល់សម្ភាសន៍

យោងតាមទិន្នន័យទទួលបានពីការផ្ដល់សម្ភាសន៍ ក្នុងចំណោម ២៥៨ នាក់ យើងសង្កេតឃើញថាចំនួនអ្នកផ្ដល់សម្ភាសន៍ដែលជាមន្ត្រីរាជការមានមធ្យមភាគខ្ពស់ជាងគេគឺ ៤៣%។ ដោយឡែកអ្នកផ្ដល់សម្ភាសន៍ដែលប្រកបរបរជាម្ចាស់ចំការមានចំនួន ២០,៨%។ ចំណែកឯអ្នកផ្ដល់សម្ភាសន៍ដែលជាអាជីវករមានចំនួន ១៨,១%។ រីឯអ្នកផ្ដល់សម្ភាសន៍ដែលជាបុគ្គលិកឯកជនមានចំនួន ១៥,៧%។ ក្រៅពីអ្នកផ្ដល់សម្ភាសន៍ដែលមានមុខរបរនិងតួនាទីការងារខាងលើគឺផ្សេងៗមានចំនួន ២,៤%។

## ដ្យាក្រាមទី៤៖ តួនាទីរបស់អ្នកផ្ដល់សម្ភាសន៍



## ៥.៣.ការវាយតម្លៃលើទំនុកចិត្ត និងប្រសិទ្ធិភាព នៃអនុវត្តលទ្ធកម្ម សាធារណៈនៅរដ្ឋបាលខេត្តប៉ៃលិន

យោងតាមលទ្ធផលនៃការស្រង់មតិរបស់អ្នកផ្តល់សម្ភាសន៍ចំនួន **២៥៨ នាក់** ដែលសុទ្ធសឹងជាប្រជាពលរដ្ឋ និងមន្ត្រីថ្នាក់មូលដ្ឋានកំពុងរស់នៅ និងប្រកបរបរនៅក្នុងខេត្តប៉ៃលិនបានបង្ហាញឱ្យឃើញថា មានមធ្យមភាគ Weight Arithmetic Mean= **៣.៨៥៥៨** និងបម្រែបម្រួលស្តង់ដា **០.៥៨៨៥** គឺជាកត្តាដែលបានជះឥទ្ធិពលយ៉ាងខ្លាំងបំផុតដល់ទំនុកចិត្ត និងប្រសិទ្ធិភាពនៃការអនុវត្តនីតិវិធីលទ្ធកម្មសធារណនៅរដ្ឋបាលខេត្តប៉ៃលិន។ ទន្ទឹមនឹងនេះ ភាពសន្សំសំចៃ, ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការអនុវត្តលទ្ធកម្មសាធារណៈជាបន្តបន្ទាប់។

**<u>តារាងទី៣៖ មធ្យមភាគ និងបម្រែបម្រួលស្តង់ដានៃសម្មតិកម្ម</u>**

| **សម្មតិកម្ម** | **ចំនួន** (n) | **មធ្យមភាគ** (Mean) | **បម្រែបម្រួលស្តង់ដា** (SD) |
|---|---|---|---|
| ការយល់ដឹង និង សមត្ថភាពមន្ត្រី | 258 | 3.7884 | 0.7348 |
| ការសន្សំសំចៃ | 258 | 3.5458 | 0.6923 |
| តម្លាភាព និង គណនេយ្យភាព | 258 | 3.7003 | 0.6422 |
| ការប្រកួតប្រជែង | 258 | 3.9725 | 0.8754 |

ស្តង់ដាវាយតម្លៃ (១.មិនយល់ស្របខ្លាំង ២.មិនយល់ស្រប ៣.មិនសម្រេចចិត្ត ៤.យល់ស្រប ៥.យល់ស្របខ្លាំង)

## ៥.៤.វិភាគផលប៉ះពាល់លើទំនុកចិត្ត និងប្រសិទ្ធិភាពនៃអនុវត្តលទ្ធកម្ម សាធារណនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅខេត្តប៉ៃលិន

គោលបំណងនៃការវិភាគសមីការ Regression និងការវិភាគម៉ូដែល ការវិភាគ ANOVA និងការវិភាគ Regression Coefficients ដែលមានលក្ខខណ្ឌឈានទៅរកភាពល្អប្រសើរនៃទិន្នន័យ។

ដើម្បីឈានទៅដល់ការបកស្រាយលើទិន្នន័យដែលទទួលបានតាមរយៈការវិភាគ ការសិក្សានេះនឹងបង្ហាញ ពីចំណុចសំខាន់នៃការគណនា និងការបកស្រាយលើអថេរនីមួយៗ ដូចជាអថេរឯក

រាជ្យ រួមមានការយល់ដឹង និងសមត្ថភាពមន្ត្រី, ការសន្សំសំចៃលទ្ធកម្ម, តម្លាភាព និងគណនេយ្យភាក្នុងការអនុវត្តការងារលទ្ធកម្ម, ការប្រកួតប្រជែង និងអថេរពឹងផ្អែក គឺជាទំនុកចិត្ត និងប្រសិទ្ធិភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈ។

**តារាងទី៤៖ ការវិភាគតាមសមីការ**

| **អថេរពឹងផ្អែក** | Multiple R = 0.591<br>R Square = 0.696<br>R-Adjust = 0.285<br>F =149.858<br>Sig=0.000 | | | | |
|---|---|---|---|---|---|
| **អថេរឯករាជ្យ** | Regression Coefficients | t-value | Sig | Collinearity | |
| | | | | Tolerance | VIF |
| ការយល់ដឹង និងសមត្ថភាពមន្ត្រី | 0.335 | 3.978 | 0.000 | 0.745 | 1.199 |
| ការសន្សំសំចៃ | 0.211 | 2.549 | 0.002 | 0.989 | 1.001 |
| តម្លាភាព និងគណនេយ្យភាព | 0.128 | 3.355 | 0.000 | 0.752 | 1.365 |
| ការប្រកួតប្រជែង | 0.132 | 0.407 | 0.001 | 0.855 | 1.188 |

ដោយយោងតាមទិន្នន័យដែលវិភាគបានទៅលើការស្រង់មតិចំនួន ២៥៨ នាក់ លទ្ធផលនៃតារាងខាងលើបានបង្ហាញថា Multiple R=0.៥៩១ មានន័យថាកម្លាំងទំនាក់ទំនងរវាងអថេរឯករាជ្យ សម្មតិកម្មទាំង ៤ រួមមាន (ការយល់ដឹង និងសមត្ថភាពរបស់មន្ត្រី , ការសន្សំសំចៃ, តម្លាភាព និងគណនេយ្យភាព, និងការប្រកួតប្រជែង) ពិតជាមានកម្លាំងទំនាក់ទំនងគ្នាមួយនឹងការទុកចិត្តនៃប្រព័ន្ធលទ្ធកម្មសាធារណៈបានចំនួន ៥៩.១%។

តាមការគណនាបានឱ្យឃើញថា R Square = 0.៦៩៦ គឺតំណាងឱ្យម៉ូដែននៃ Regression ដែលបង្ហាញពីទំនាក់ទំនងរវាងបម្រែបម្រួលគម្លាតស្តង់ដា (SD) រវាងអថេរឯករាជ្យជាមួយ អថេរពឹងផ្អែកពោលគឺអថេរពឹងផ្អែកត្រូវបានពន្យល់ដោយអថេរឯករាជ្យបានចំនួន

៦៩.៦%។ នោះមានន័យថា មានអថេរឯករាជ្យចំនួន ៣០.៤% ដែលមិនបានលើកមកនិយាយក្នុងម៉ូដែល។ ដូច្នេះចំនួន ៣០.៤% ហៅថា Distribution terms ឬ Error terms។

ចំណែកឯ F=១៤៩.៨៥៨, P = 0.000<0.0១ មានន័យថាតម្លៃ F មានសារៈសំខាន់នៅកម្រិត ១%។ មានន័យថាអថេរឯករាជ្យ (ការយល់ដឹង និងសមត្ថភាពមន្ត្រីមូលដ្ឋាន, ការសន្សំសំចៃលទ្ធកម្ម. តម្លាភាព និងគណនេយ្យភាព, និងការប្រកួតប្រជែង) បានចូលរួមជះឥទ្ធិពលដល់អថេរពឹងផ្អែក( ទំនុកចិត្តនិង ប្រសិទ្ធិភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈ)។

**ក្រៅពីនេះលទ្ធផលនៃ Regression Coefficients បានបង្ហាញដូចខាងក្រោម៖**

## ១.ការយល់ដឹង និងសមត្ថភាពមន្ត្រីមូលដ្ឋាន

លទ្ធផលនៃការវិភាគសមីការ Regression បានបង្ហាញថា b=0.335, t=3.978, p-value=0.000 < 1% មានន័យថាអថេរឯករាជ្យ ពិតជាមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយអថេរពឹងផ្អែកនៅកម្រិត១%។ យោងតាមលទ្ធផលនេះ **សម្មតិកម្មទី១ ៖ ការយល់ដឹង និងសមត្ថភាពមន្ត្រីមូលដ្ឋាន** មិនមានផលប៉ះពាល់ជាវិជ្ជមាន និងសារៈសំខាន់ទៅលើទំនុកចិត្ត និងប្រសិទ្ធិភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈ "ត្រូវបដិសេធ"។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានបានថា ការយល់ដឹង និងសមត្ថភាពមន្ត្រីមូលដ្ឋានពិតជាមានការជះឥទ្ធិពលដល់ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តលទ្ធកម្មសាធារណរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិនពិតប្រាកដមែន។

## ២.ការសន្សំសំចៃក្នុងការអនុវត្តកិច្ចលទ្ធកម្ម

លទ្ធផលនៃការវិភាគសមីការ Regression បានបង្ហាញថា b=0.211, t=2.549, p-value=0.002 < 1% មានន័យថាអថេរឯករាជ្យ ពិតជាមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយអថេរពឹងផ្អែកនៅកម្រិត១%។ យោងតាមលទ្ធផលនេះ **សម្មតិកម្មទី២ ៖ ការសន្សំសំចៃ** មិនមានផលប៉ះពាល់ជាវិជ្ជមាន និងសារៈសំខាន់ទៅលើទំនុកចិត្ត និងប្រសិទ្ធិភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈ "ត្រូវបដិសេធ"។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានបានថា **ការសន្សំសំចៃក្នុងការអនុវត្តការងារលទ្ធកម្មសាធារណៈ** ពិតជាមានការជះឥទ្ធិពលដល់ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តលទ្ធកម្មសាធារណរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិនពិតប្រាកដមែន។

## ៣.តម្លាភាព និងគណនេយ្យភាព ក្នុងការអនុវត្តការងារលទ្ធកម្ម

លទ្ធផលនៃការវិភាគសមីការ Regression បានបង្ហាញថា b=0.128, t=3.355, p-value=0.000 < 1% មានន័យថាអថេរឯករាជ្យ ពិតជាមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយអថេរពឹងផ្អែកនៅកម្រិត១%។ យោងតាមលទ្ធផលនេះ **សម្មតិកម្មទី៣ ៖ តម្លាភាពនិងគណនេយ្យភាព**

ក្នុងការអនុវត្តការងារលទ្ធកម្មសាធារណៈ មិនមានផលប៉ះពាល់ជាវិជ្ជមាន និងសារៈសំខាន់ទៅលើទំនុកចិត្ត និងប្រសិទ្ធិភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈ "ត្រូវបដិសេធ"។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានបានថា **តម្លាភាព និងគណនេយ្យភាពក្នុងការអនុវត្តការងារលទ្ធកម្មសាធារណៈ** ពិតជាមានការជះឥទ្ធិពលដល់ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តលទ្ធកម្មសាធារណរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិនពិតប្រាកដមែន។

## ៤.ការប្រកួតប្រជែងក្នុងការអនុវត្តការងារលទ្ធកម្ម

លទ្ធផលនៃការវិភាគសមីការ Regression បានបង្ហាញថា b=0.132, t=0.407, p-value=0.001 < 1% មានន័យថាអថេរឯករាជ្យ ពិតជាមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយអថេរពឹងផ្អែកនៅកម្រិត១%។ យោងតាមលទ្ធផលនេះ **សម្មតិកម្មទី៤ ៖ ការប្រកួតប្រជែងក្នុងការអនុវត្តការងារលទ្ធកម្មសាធារណៈ** មិនមានផលប៉ះពាល់ជាវិជ្ជមាន និងសារៈសំខាន់ទៅលើទំនុកចិត្ត និងប្រសិទ្ធិភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈ "ត្រូវបដិសេធ"។ ហេតុដូច្នេះ យើងអាច សន្និដ្ឋានបានថា **ការប្រកួតប្រជែងក្នុងការអនុវត្តការងារលទ្ធកម្មសាធារណៈ** ពិតជាមានការជះឥទ្ធិពលដល់ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តលទ្ធកម្មសាធារណរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិនពិតប្រាកដមែន។

តបតាមការបកស្រាយខាងលើបានបង្ហាញថា សម្មតិកម្មទាំង ៤ សុទ្ធសឹងតែជាកត្តា ជះឥទ្ធិពលដល់ទំនុកចិត្ត និងប្រសិទ្ធិភាពនៃការអនុវត្តលទ្ធកម្មសាធារណៈរបស់រដ្ឋបាលខេត្តប៉ៃលិន។ ពោលគឺប្រជាពលរដ្ឋនៅទីនោះភាគច្រើនឱ្យតម្លៃទៅលើការចូលរួមសហការគ្នាទៅវិញទៅមករវាងអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ដែលកត្តាជម្រុញឱ្យមានការអភិវឌ្ឍ និងភាគរីកចម្រើននៅក្នុងមូលដ្ឋាន។

# ជំពូកទី ៦

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៦.១.សេចក្តីផ្តើម

គោលបំណងនៃជំពូកនេះនឹងផ្តោតទៅលើការសង្ខេបនៃលទ្ធផលដែលបានរកឃើញជាលើកចុងក្រោយ។ ដើម្បីកំណត់នូវកត្តាកំណត់ទំនុកចិត្ត និងប្រសិទ្ធិភាពនៃការអនុវត្តលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ខេត្តប៉ៃលិន។ អាស្រ័យហេតុនេះ ជំពូកនេះ ត្រូវបានបែងចែកជា ៣ ផ្នែកតូចៗ ដូចជា៖ ផ្នែកទី១ ការសង្ខេបអំពីលទ្ធផល ផ្នែកទី២ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ និងផ្នែកទី៣ ការស្រាវជ្រាវនាថ្ងៃអនាគត។

## ៦.២ សង្ខេបលទ្ធផល

ផ្អែកតាមលទ្ធផលនៃការវិភាគទិន្នន័យ បានបង្ហាញថាលទ្ធផលមធ្យមមេគុណរបស់ អថេរទាំង ០៤ រួមមាន ការយល់ដឹង និងសមត្ថភាពមន្ត្រីមូលដ្ឋាន, ការសន្សំសំចៃ, តម្លាភាព និងគណនេយ្យភាព, និងការប្រកួតប្រជែង មានទំនោរខិតទៅរកកម្រិតភាពពេញចិត្ត។ ចំណែកឯលទ្ធផលនៃរ៉េហ្គ្រេសិន បានរកឃើញថាអថេរឯករាជ្យទាំង ៤ សុទ្ធតែមានទំនាក់ទំនងជាមួយអថេរពឹងផ្អែកនូវកម្រិត ៥% និង ១%។ ដូច្នេះសម្មតិកម្មសូន្យទាំង ៤ ត្រូវបានតេស្តដូចខាងក្រោមនេះ៖

**សម្មតិកម្មសូន្យទី១ ៖ការយល់ដឹង និងសមត្ថភាពរបស់មន្ត្រី** មិនមានផលប៉ះពាល់ជាវិជ្ជមាន និងសារៈសំខាន់ទៅលើ ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តកិច្ចលទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន "ត្រូវបដិសេធ"។

**សម្មតិកម្មសូន្យទី២ ៖ការសន្សំសំចៃ** មិនមានផលប៉ះពាល់ជាវិជ្ជមាន និងសារៈសំខាន់ទៅលើ ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តកិច្ចលទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន "ត្រូវបដិសេធ"។

**សម្មតិកម្មសូន្យទី៣ ៖តម្លាភាព និងគណនេយ្យភាព** មិនមានផលប៉ះពាល់ជាវិជ្ជមាន និងសារៈសំខាន់ទៅលើ ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តកិច្ចលទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន "ត្រូវបដិសេធ"។

**សម្មតិកម្មសូន្យទី៤ ៖ការប្រកួតប្រជែង** មិនមានផលប៉ះពាល់ជាវិជ្ជមាន និងសារៈសំខាន់ទៅលើ ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តកិច្ចលទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន "ត្រូវបដិសេធ"។

## ៦.៣ សេចក្តីសន្និដ្ឋាន

សរុបមកផ្អែកលើលទ្ធផលខាងលើ អថេរនៃសូចនាករនៃកត្តាកំណត់នៃការចូលរួមរបស់ប្រជាពលរដ្ឋ និងមន្ត្រីមូលដ្ឋានរួមមាន៖ ការយល់ដឹង និងសមត្ថភាពមន្ត្រី, ការសន្សំសំចៃក្នុងកិច្ចលទ្ធកម្ម, តម្លាភាព និងគណនេយ្យភាពនៃលទ្ធកម្ម, និងការប្រកួតប្រជែងដោយភាពយុត្តិធម៌ សុទ្ធតែមានផលប៉ះពាល់ជាវិជ្ជមាននិងសំខាន់ទៅលើទំនុកចិត្ត និងប្រសិទ្ធិភាពនៃការអនុវត្តលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន។ ដូច្នេះការសិក្សានេះអាចវាយតម្លៃថា ប្រជាពលរដ្ឋ និងមន្ត្រីមូលដ្ឋានដែលកំពុងរស់នៅក្នុងខេត្តប៉ៃលិន មានភាពពេញចិត្តខ្លាំងចំពោះការអនុវត្តលទ្ធកម្មសាធារណៈ និងចូលរួមសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន ព្រមទាំងរួមចំណែកយ៉ាងសកម្មធ្វើឱ្យរដ្ឋបាលខេត្តមានទំនុកចិត្ត និងប្រសិទ្ធិភាព ក្នុងអភិបាលកិច្ចល្អ ដើម្បីអភិវឌ្ឍហេដ្ឋានរចនាសម្ព័ន្ធ សេដ្ឋកិច្ចជីវភាពប្រជាពលរដ្ឋស្របតាមកម្មវិធីគោលនយោបាយកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

## ៦.៤ អនុសាសន៍

យោងតាមសេចក្តីសន្និដ្ឋាននៃលទ្ធផលខាងលើ បានជួយផ្តល់ជាព័ត៌មានដល់អ្នកធ្វើគោលនយោបាយ ឬអ្នកធ្វើផែនការ ឱ្យរៀបចំផែនការអភិវឌ្ឍ គោលនយោបាយ សេដ្ឋកិច្ច ការអភិវឌ្ឍ និងពង្រឹងធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីរាជការ នៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់រីចម្រើន និងមានប្រសិទ្ធិភាព តម្លាភាព និងគណនេយ្យភាពកាន់តែប្រសើរឡើងថែមទៀត។ ដូច្នេះអាជ្ញាធរមូលដ្ឋានគួរបន្តអនុវត្តផែនការសកម្មភាពមួយចំនួនដូចខាងក្រោម៖

- បន្តការរៀបចំកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា វិក្រឹតការ និងវគ្គសិក្សាផ្សេងៗ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្របតាមយុទ្ធសាស្ត្រ
- បន្តផ្សព្វផ្សាយចំណេះដឹងស្តីពីការអប់រំ គោលនយោបាយ ផែនការអភិវឌ្ឍមូលដ្ឋាន ហេដ្ឋានរចនាសម្ព័ន្ធ ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ
- បន្តផ្សព្វផ្សាយជាសាធារណៈ ជាពិសេសព័ត៌មានអំពីការដេញថ្លៃប្រកួតប្រជែង បើកចំហចំពោះសាធារណៈជនពាក់ព័ន្ធលទ្ធកម្មសាធារណ លើកលែងតែព័ត៌មានមួយចំនួនដែលមានការសម្ងាត់ និងវេតទយិតខ្ពស់
- បន្តលើកទឹកចិត្តអ្នកដេញថ្លៃក្នុងស្រុកឱ្យចូលរួមក្នុងលទ្ធកម្មសាធារណៈដើម្បីបង្កើនប្រសិទ្ធិភាពនូវការប្រកួតប្រជែង
- បន្តពង្រឹងអភិបាលកិច្ចល្អ តាមរយៈការបង្កើនការសន្សំសំចៃចំណាយរដ្ឋបាល ដែលមិនចាំបាច់

- បន្តពង្រឹងសកម្មភាពត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្ម ទាំងលើកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិការដ្ឋ និងកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ
- បន្តពង្រឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយវិជ្ជាជីវៈ ឱ្យបានឆាប់រហ័ស ទាន់ចិត្ត តម្លាភាព និងគណនេយ្យភាព ជានិរន្តភាព

## ៦.៥ ដែនកំណត់ និងការស្រាវជ្រាវនាអនាគត

ដោយផ្អែកលើដែនកំណត់នៃការសិក្សាបច្ចុប្បន្នដូចបានរៀបរាប់ក្នុងជំពូកទី១ វិសាលភាពសម្រាប់ការស្រាវជ្រាវបន្ថែមនេះត្រូវបានបង្ហាញដូចខាងក្រោម៖

១. ស្វែងយល់ពីឥរិយាបថរបស់ប្រជាពលរដ្ឋក្នុងការស្វែងរកការប្រើប្រាស់ និងការយល់ដឹងអំពីលទ្ធកម្មសាធារណៈ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅខេត្តប៉ៃលិន ដោយធ្វើការសម្ភាសន៍ប្រជាពលរដ្ឋ និងមន្រ្តីមូលដ្ឋាន ចំនួន ២៨៥ នាក់តែប៉ុណ្ណោះ ដែលត្រូវបានជ្រើសរើសជាទំហំសំណាក។ ការសិក្សានេះអាចផ្តល់លទ្ធផលកាន់តែល្អប្រសើរជាងនេះ បើសិនជាទំហំនៃសំណាកអាចបង្កើនច្រើនជាងការសិក្សាបច្ចុប្បន្ននេះ។

២. ដើម្បីពិនិត្យមើលលើកត្តាកំណត់ទំនុកចិត្ត និងប្រសិទ្ធិភាពលើការអនុវត្តលទ្ធកម្មសាធារណៈ អថេរឯករាជ្យដូចជា ការយល់ដឹង និងសមត្ថភាពមន្រ្តី, ការសន្សំសំចៃ, តម្លាភាព និងគណនេយ្យភាព និងការប្រកួតប្រជែង ដែលការសិក្សាបច្ចុប្បន្ននេះបានលើមកពិចារណា។ ការសិក្សាអាចផ្តល់នូវលទ្ធផលល្អប្រសើរជាងនេះ បើសិនជាអថេរឯករាជ្យ នឹងបង្កើនចំនួនច្រើនជាងការសិក្សាបច្ចុប្បន្ន។

៣. សម្រាប់និស្សិត អ្នកស្រាវជ្រាវជំនាន់ក្រោយ នាពេលអនាគតអាចពិចារណាលើផ្អែកផ្សេងៗទៀត រួមទាំង រាជធានី ខេត្ត ដទៃទៀតក្នុងប្រទេសកម្ពុជា ដែលកំពុងអនុវត្តលទ្ធកម្មសាធារណៈ ឬគ្រឹះស្ថានរដ្ឋបាលសាធារណ ឬសហគ្រាសជារណៈ ដើម្បីវាយតម្លៃទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តកិច្ចលទ្ធកម្ម។ ដូច្នេះ ដែនកំណត់នៃការសិក្សាបច្ចុប្បន្នបានផ្តល់ជាមូលដ្ឋាននៃការយល់ដឹងសម្រាប់ការស្រាវជ្រាវបន្ថែមក្នុងវិស័យរដ្ឋបាលថ្នាក់ក្រោមជាតិ។

សរុបជារួមមក ការសិក្សាបច្ចុប្បន្នបានព្យាយាមធ្វើការវិភាគទិន្នន័យដោយប្រើទំហំសំណាកបន្ថែមទៀត និងវាយតម្លៃកត្តាកំណត់ទំនុកចិត្ត និងប្រសិទ្ធិភាពនៃការអនុវត្តលទ្ធកម្មសាធារណៈ ដោយប្រើអថេរឯករាជ្យបន្ថែមទៀត នៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា។

# ឯកសារយោង


Arciniegas Parra Juan David, (2024) Public Procurement, The Jusmundi, Public Procurement

Arrowsmith, S. (2010). Public procurement: Basic concepts and coverage of procurement rules in procurement relations: An introduction. EU: Asia Inter University Network.

Asian Development Bank (2017), ADB Procurement Policy, Goods, Works, Nonconsulting and Consulting Service, IGO license (CC BY-NC-ND 3.0 IGO), Philippine. ADB Procurement Policy: Goods, Works, Nonconsulting and Consulting Services

Asian Development Bank (ADB). (2018). Public Procurement in Cambodia: Challenges and Reforms. ADB Publications.

Australian Government, Department of Finance (2024), Commonwealth Procurement Rules, ISBN: 978-1-925205-60-2, Commonwealth Procurement Rules 2024

Basheka, B. C. &Bisangabasaija, E. (2010). Determinants of unethical public procurement in local governmentsystems of Uganda: a case study. *Int. J. Procurement Management*, 3(1),

Buchanan, J. M., & Tullock, G. (1962). The Calculus of Consent: Logical Foundations of Constitutional Democracy. University of Michigan Press.

Callendar, G. & Mathews, D. (2000). ―Government Purchasing: An Evolving Profession?‖ *Journal of PublicBudgeting, Accounting & Financial Management*

Daniel Pye (2014), Global Fund's probe saw little cooperation | The Phnom Penh Post Global Fund's probe saw little cooperation | Phnom Penh Post

Jensen, M. C., & Meckling, W. H. (1976). "Theory of the Firm: Managerial Behavior, Agency Costs, and Ownership Structure." Journal of Financial Economics, 3(4), 305-360.

Lukas Vogel (2009), Macroeconomic effects of cost of saving in public procurement, ISBN 978-92-79-13364-0, European Communities. Macroeconomic effects of cost savings in public procurement

Ministry of Economy and Finance (MEF), Cambodia. (2006). Law on Public Procurement. Available at: mef.gov.kh

Ministry of Economy and Finance, Cambodia. (2006). Procurement Sub-Decree No. 105 ANK/BK (2006).

Ministry of Economy and Finance, Cambodia. (2016). Public Procurement Guidelines.

Oakley, (1991) Projects with People: The Practice of Participation in Rural Development,

OECD. (2019). OECD Public Procurement Toolbox: Enhancing Efficiency and Transparency.

Odhiambo, W and Kamau, P (2003) The integration of developing countries into the world trading system. *Public procurement lessons from Kenya, Tanzania and Uganda, available on* http:/www.oecd.org, on 15th Dec. 2009.

Rules of thumb for minimum sample size for multiple regression.2002 (n.d.). Cross Validated. https://stats.stackexchange.com/questions Newest Questions - Cross Validated

Thai, K. V. (2009). International Handbook of Public Procurement. CRC Press.

Transparency International Cambodia. (2020). Corruption Risk in Public Procurement. Available at: ticambodia.org

Transparency International. (2020). Corruption Perceptions Index: Cambodia.

UNDP (2012), Annual Statistical Report on United Nations Procurement, Transparency and public procurement.

Understanding the bidding process and procedures for the procurement of goods work and services: https://www.theijes.com/papers/v2-i11/Part.3/E021103024030.pdf

Witting, W. A. (1999). Building value through public procurement, A focus on Africa: Durban: 9th international anti- corruption conference, 10-15 October. Durban: South Africa

World Bank. (2015). Enhancing Public Procurement Systems: Cambodia Report.

World Bank, (2015), The Public Procurement Laws. Law No. 124-2012, 14-2015 and 68-2015 on Public Procurement.pdf

World Bank. (2017). Procurement Reforms: Case Studies from Developing Countries.

World Bank (2017), Bank Policy, Procurement in IPF and Other Operational Procurement Matters, OPSVP5.05-POL.144, Bank-Policy-Procurement-in-IPF-and-Other-Operational-Procurement-Matters.pdf

World Bank. (2022). Public Procurement in Cambodia: Governance and Reforms. World Bank Reports.

គ.ជ.អ.ប – National Committee for Sub-National Democratic Development,

https://ncdd.gov.kh

ព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ស្តីពីច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣

អនុក្រឹត្យលេខ ១០៥ អនក្រ.បក ស្តីពីលទ្ធកម្មសាធារណៈ

អនុក្រឹត្យលេខ ១៣ អនក្រ.បក ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រើព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម

អនុក្រឹត្យលេខ ២១ អនក្រ.បក ស្ដីពីបែបបទនិងនីតិវិធីនៃការប្ដឹង និងការដោះស្រាយបណ្ដឹងលទ្ធកម្ម

ប្រកាសលេខ ៨៣៣ សហវ.ប្រក.អលសា. ស្ដីពីការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម

ប្រកាសលេខ ៨៣១ សហវ.ប្រក.អលសា. ស្ដីពីការពិនិត្យ និងអនុម័តផែនការលទ្ធកម្មរបស់មន្ទីរជំនាញរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ប្រកាសលេខ ៩៨៧ សហវ.ប្រក ស្ដីពីក្រមសីលធម៌លទ្ធកម្ម

ប្រកាសលេខ ២៤៩ សហវ.ប្រក ស្ដីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា

យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥

អង្គការទិន្នន័យអំពីការអភិវឌ្ឍ (២០១៥), លទ្ធកម្ម, លទ្ធកម្ម_| Open Development Cambodia (ODC)

រដ្ឋបាលខេត្តប៉ៃលិន Pailin Home Page (KM) - រដ្ឋបាលខេត្តប៉ៃលិន

# ឧបសម្ព័ន្ធ

ការស្រង់មតិនេះត្រូវបានរៀបចំឡើងដើម្បីសិក្សាអំពីកត្តាកំណត់ទំនុកចិត្ត និងប្រសិទ្ធិភាព នៃការអនុវត្តលទ្ធកម្មសាធារណៈរបស់រដ្ឋបាលខេត្តប៉ៃលិន និងស្វែងយល់អំពីបញ្ហាប្រឈមនានាក្នុងដំណើរការអនុវត្តរដ្ឋបាលខេត្តប៉ៃលិន។ កម្រងសំណួរនេះ គឺរៀបចំឡើងក្នុងគោលបំណងសិក្សាស្រាវជ្រាវ ដើម្បីអាចឈានទៅបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញរដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។ សូមមេត្តាឆ្លើយដោយស្មោះត្រង់ពីទិន្នន័យនៅក្នុងកម្រងសំណួរនេះដែលនឹងត្រូវយកមកវិភាគទាល់តែជាប្រភពទិន្នន័យដែលត្រឹមត្រូវពិតប្រាកដជាក់លាក់ និងឱ្យទុកចិត្តបាន។

*ចម្លើយ និងមតិយោបល់នេះនឹងត្រូវបានរក្សាការសម្ងាត់។

## សេចក្តីណែនាំ

សូមគូសសញ្ញា (√)នៅក្នុងប្រអប់ចម្លើយ ឬបំពេញព័ត៌មានដែលស្នើសុំឱ្យបានត្រឹមត្រូវ

សូមគូសរង្វង់លេខណាមួយដែលជាចំណាត់ថ្នាក់ សម្រាប់លោកអ្នកគិតថា វាត្រឹមត្រូវតាមស្ថានភាពពិតប្រាកដ។

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

## ១. ព័ត៌មានទូទៅ

១. អាយុ: ក.១៨-២៥ ☐ ខ.២៥-៣៥ ☐ គ.៣៥-៤៥ ☐ ឃ.>45 ☐

២. ភេទ:

ក.ប្រុស. ☐ ខ.ស្រី ☐

៣. កម្រិតសិក្សា

ក. អនុវិទ្យាល័យ ☐ ខ. វិទ្យាល័យ ☐ គ. ថ្នាក់បរិញ្ញាបត្រ ☐

ឃ. បរិញ្ញាបត្រជាន់ខ្ពស់ ☐ ង. ថ្នាក់បណ្ឌិត ☐

៤. មុខរបរ ឬការងារ

ក. មន្ត្រីរាជការ ☐ ខ. អាជីវករ ☐ គ. បុគ្គលិកឯកជន ☐

ឃ. ម្ចាស់ចំការ ឬកសិករ ☐ ង. ផ្សេងៗ ☐

## ២. ការយល់ដឹង និងសមត្ថភាពមន្ត្រី និងប្រជាពលរដ្ឋ

១.មន្ត្រីរាជការ នៃរដ្ឋបាលខេត្តប៉ៃលិន មានសញ្ញាបត្រ ឬវិញ្ញាបនបត្រពាក់ព័ន្ធនឹងជំនាញហិរញ្ញវត្ថុសាធារណៈ, គណនេយ្យ ឬជំនាញប្រហាក់ប្រហែល

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

២.មន្ត្រីរាជការនៃរដ្ឋបាលខេត្តប៉ៃលិន មានបទពិសោធន៍ការងារគ្រប់គ្រាន់

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

៣.ប្រជាពលរដ្ឋមានការយល់ដឹងអំពីច្បាប់ ឬការអនុវត្តច្បាប់ត្រឹមត្រូវ

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

៤. ការយល់ដឹងរបស់ប្រជាពលរដ្ឋជាភាពចាំបាច់ចំពោះការវាយតម្លៃប្រសិទ្ធិភាពនៃការអនុវត្តសេវាសាធារណៈសម្រាប់ការអភិវឌ្ឍក្នុងខេត្តប៉ៃលិន

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

៥.ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងមន្ត្រីជាផ្នែកមួយដែលគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឱ្យរីកចម្រើន មានតម្លាភាព និងគណនេយ្យភាព

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

## ៣. ការសន្ទំសំចៃ

១. ខេត្តប៉ៃលិនទទួលបានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ សម្រាប់បំរើដល់សេវាសាធារណៈជូនប្រជាពលរដ្ឋទាន់ពេលវេលា និងឆាប់រហ័យ

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

២.ក្រុមហ៊ុន សហគ្រាស និងអ្នកដេញថ្លៃជាច្រើនបានចូលរួមដាក់សំណើដេញថ្លៃប្រកួតប្រជែងគម្រោងផែនការសាងសង់ផ្លូវ ថ្នល់ អគាររដ្ឋបាល សាលារៀនក្នុងខេត្តប៉ៃលិន

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

៣.អាជ្ញាធរមូលដ្ឋានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបំរើសេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធិភាព គុណភាព និងភាពថ្លៃថ្នូរ

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

៤.ផ្លូវថ្នល់នៅក្នុងខេត្តប៉ៃលិនមានភាពល្អប្រសើរ និងងាយស្រួលសម្រាប់ប្រជាពលរដ្ឋធ្វើដំណើរបំពេញការងារ ការលក់ដូរ ធ្វើអាជីវកម្ម

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

៥.អាជ្ញាធរមូលដ្ឋានបានចុះត្រួតពិនិត្យមើលរាល់សំណង់អគាររដ្ឋបាលចាស់ទ្រុឌទ្រោមនិងជួសជុលកែលម្អឡើងវិញទាន់ពេលវេលាប្រកបដោយគុណភាពល្អ

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

## ៤. តម្លាភាព និងគណនេយ្យភាព

១.ប្រជាពលរដ្ឋ ងាយស្រួលទទួលបានព័ត៌មានផ្សព្វផ្សាយអំពីកិច្ចការងារក្នុងវិស័យលទ្ធកម្មសាធារណៈតាមរយៈសារព័ត៌មាន ការសែត អ៊ីនធើណេតគ្រប់គ្រាន់

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

២.សេចក្តីជូនដំណឹងអំពីការដេញថ្លៃ ការលក់ឯកសារដេញថ្លៃ ត្រូវបានផ្សព្វផ្សាយដោយបើកចំហ និងយ៉ាងទូលំទូលាយដល់សាធារណៈជនគ្រប់រូប

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

៣.អាជ្ញាធរមូលដ្ឋានបានលើកទឹកចិត្តដល់សហគ្រាសធុនមីក្រូ តូច មធ្យម ឱ្យចូលរួមប្រកួតប្រជែងដេញថ្លៃជាសាធារណៈ តាមរយៈការផ្តល់ប្រព្រឹត្តកម្មអនុគ្រោះ

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

៤.គម្រោងផែនការសាងសង់ផ្លូវថ្នល់ដោយប្រើប្រាស់ថវិកាដៃគូអភិវឌ្ឍក្នុងខេត្តប៉ៃលិនត្រូវបានផ្សព្វផ្សាយជាមួយនឹងទំហំមូលនិធិត្រឹមត្រូវ និងជាក់លាក់

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

៥.ចំនួននៃក្រុមហ៊ុន សហគ្រាស ឬអ្នកដេញថ្លៃបានកើនឡើងក្នុងការដេញថ្លៃប្រកួតប្រជែងគម្រោងលទ្ធកម្ម ជាការគាំទ្រដល់តម្លាភាព និងគណនេយ្យភាព

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

## ៥. ការប្រកួតប្រជែង

១. ក្រុមហ៊ុន សហគ្រាស យ៉ាងតិចចំនួន ០៣ ត្រូវបានចូលរួមប្រកួតប្រជែងក្នុងការដេញថ្លៃគម្រោងលទ្ធកម្ម រួមទាំងទំនិញ សំណង់ និងសេវាកម្មក្នុងខេត្តប៉ៃលិន

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

២.សេចក្តីជូនជូនដំណឹងអំពីការសម្រេចប្រគល់កិច្ចសន្យាដល់ក្រុមហ៊ុន ឬអ្នកដេញថ្លៃឈ្នះ ត្រូវបានចម្លងជូនដល់ភាគីដទៃទៀត ឬអ្នកដេញជ្រាបជាព័ត៌មាន

- ១.មិនយល់ស្របខ្លាំង ☐
- ២.មិនយល់ស្រប ☐
- ៣.មិនសម្រេចចិត្ត ☐
- ៤.យល់ស្រប ☐
- ៥.យល់ស្របខ្លាំង ☐

៣.នីតិវិធីនៃការបើក និងទទួលសំណើដេញថ្លៃមានលក្ខណប្រកួតប្រជែងពិតប្រាកដជាមូលដ្ឋាននៃការទទួលបានការសន្សំសំចៃលើចំណាយរបស់រដ្ឋបាលខេត្តប៉ៃលិន

- ១.មិនយល់ស្របខ្លាំង ☐
- ២.មិនយល់ស្រប ☐
- ៣.មិនសម្រេចចិត្ត ☐
- ៤.យល់ស្រប ☐
- ៥.យល់ស្របខ្លាំង ☐

៤.អ្នកចូលរួមប្រកួតប្រជែងពិតជាមិនមានទំនាក់ទំនងជាសាច់ញ្ញាតិ ឬមិត្តភក្តិជាមួយនឹងមន្ត្រីរដ្ឋបាលខេត្តប៉ៃលិន

- ១.មិនយល់ស្របខ្លាំង ☐
- ២.មិនយល់ស្រប ☐
- ៣.មិនសម្រេចចិត្ត ☐
- ៤.យល់ស្រប ☐
- ៥.យល់ស្របខ្លាំង ☐

៥.អាជ្ញាធរមូលដ្ឋានរីករាយស្វាគមន៍នឹងការទទួលបណ្ដឹងតវ៉ាទាំងឡាយរបស់ប្រជាពលរដ្ឋ និងសាធារណៈជនលើកំហុសឆ្គង ឬអំពើយុតឃិត ឬបញ្ហាណាមួយកើតមានឡើងក្នុងដំណើរការកិច្ចលទ្ធកម្ម ប្រកបដោយស្មារតីទទួលខុសត្រូវ

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

សូមថ្លែងអំណរគុណសម្រាប់ការចូលរួមសហការ និងយលព្រមឆ្លើយតបទៅនឹងសំណួរ។